NGO-CEDAW

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើង
លើស្ត្រីភេទ

# របាយការណ៍តាមដានការអនុវត្ត អនុសញ្ញា ស៊ីដ ឆ្នាំ ២០១៧

ការវាយតម្លៃពីការវិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្ត
អនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់
នៃការរើសអើសលើស្ត្រីភេទ

ឧបត្ថម្ភដោយ

Canada

HEINRICH
BÖLL
STIFTUNG
CAMBODIA

បោះពុម្ពចំនួន ៥០០ ក្បាល

## គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥បន្ទាប់ពីសកម្មជនស្ត្រីមួយចំនួនបានត្រឡប់មកពីចូលរួមសន្និសិទពិភពលោកស្តីពី ស្ត្រីនៅទីក្រុងប៉េកាំង ជាមួយនឹងទស្សនៈវិស័យសម្រេចអោយបានសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ។ បេសកម្មចំបងរបស់ NGO-CEDAW គឺធ្វើការតាមដាននិងលើកកម្ពស់ការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ នៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល NGO-CEDAW មានសមាជិក ៣៧ អង្គការ ដែលកំពុងអនុវត្តសកម្មភាពគ្រប់ខេត្តនៅទូទាំងប្រទេស លើបញ្ហាចំបងៗដែលជាឧបសគ្គចំពោះសិទ្ធិស្ត្រី។

### ការតាមដាន

NGO-CEDAW បង្ហាញនូវចន្លោះខ្វះខាតរបស់រដ្ឋាភិបាលក្នុងការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដោយៈ

- បានសរសេររបាយការណ៍ស្រមោលដាក់ជូនទៅ អង្គការសហប្រជាជាតិទទួលបន្ទុកស៊ីដ។
- ដាក់ជូនព័ត៌មានទៅក្នុងដំណើរការនៃរបាយការណ៍តាមកាលកំណត់ជាសកល។
- ធ្វើការស្រាវជ្រាវផលប៉ះពាល់ដល់ស្ត្រី និងកុមារពីអំពើហិង្សាផ្អែកលើយេនឌ័រ ការកាន់កាប់ដីធ្លី និងវិធានការច្បាប់នានា ដែលគម្រាមកំហែងអ្នកការពារសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។

### ការស្វែងរកមតិគាំទ្រ

NGO-CEDAW ស្វែងរកមតិគាំទ្រអោយមានច្បាប់ដែលប្រសើរសម្រាប់ការពារសិទ្ធិស្ត្រី ដោយបញ្ចូល ទាំងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ជនពិការ អ្នកផ្ទុកមេរោគហ៊ីវ ស្ត្រីជនបទ និងសហគមន៍ជនជាតិដើមភាគតិច។

សកម្មភាពនាពេលថ្មីៗរបស់ NGO-CEDAW មានៈ

- ដឹកនាំការស្នើសុំអោយមាន ការធ្វើវិសោធន៍កម្ម វិធានផ្លូវច្បាប់ រួមមានច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។
- ផ្តួចផ្តើមការចេញសេចក្តីថ្លែងការណ៍ លើសេរីភាពក្នុងការបញ្ចេញមតិ និង បញ្ចប់អំពើហិង្សាលើស្ត្រី។
- ចូលរួមគាំទ្រលើកិច្ចពិគ្រោះយោបល់ រវាងសង្គមស៊ីវិល និងរដ្ឋាភិបាលទៅលើសេចក្តីពង្រាងច្បាប់ ស្តីពីការទទួលបានព័ត៌មាន ។

### បង្កើនការយល់ដឹងៈ

ដើម្បីសម្រេចអោយ បាននូវសមភាពយេនឌ័រ គឺទាមទារអោយមានការផ្លាស់ប្តូរការប្រព្រឹត្តពីប្រជាពរដ្ឋគ្រប់រូប ។ NGO-CEDAW បានបង្កើតអោយមាននូវកម្មវិធីអប់រំជាសាធារណៈនាឱកាសទិវានារីអន្តរជាតិក្នុងខែមិនា និងយុទ្ធនាការ ១៦ថ្ងៃ ប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ ក្នុងខែ វិច្ឆិកា និងធ្នូ។

កម្មវិធីសេចក្តីថ្លែងរបស់ NGO-CEDAW បានប្រើប្រាស់ការតាំងពិពណ៌ស្នាដៃសិល្បៈ បោះពុម្ពសៀវភៅ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីបង្ហាញពីដំណោះស្រាយនានាចំពោះអំពើហិង្សាផ្អែកលើយេនឌ័រ ។

### ការបណ្តុះបណ្តាលជំនាញៈ

បុគ្គលិកជំនាញរបស់ NGO-CEDAW ធ្វើការជាមួយសមាជិក ដោយផ្តល់ជាវគ្គបណ្តុះបណ្តាលជំនាញ និងជំនួយបច្ចេកទេសពីប្រធានបទដែលទាក់ទងនិងអនុសញ្ញា ស៊ី ដ ច្បាប់សិទ្ធិមនុស្សនានា និងការប្រើប្រាស់ឧបករណ៍តាមដាន។

NGO-CEDAW ក៏បានអនុវត្តសកម្មភាពមួយចំនួនដូចជាៈ

- បង្កើតបណ្តាញនៃអ្នកស្ម័គ្រចិត្ត នៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តនានា ។
- ផ្តល់បច្ចេកទេសដល់មន្ត្រីរដ្ឋាភិបាលពីការអនុវត្តអនុសញ្ញា **ស៊ី ដ** និងច្បាប់នានាដែលការពារស្ត្រី។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ
វេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានៈ (+៨៥៥) ១២ ៨០២ ៥០៦ អ៊ីម៉ែលៈ licadhomail@gmail.com
លោកស្រី ជឹម ចាន់នាង អគ្គលេខាធិការៈ (+៨៥៥) ១២ ៦៦៨ ៨៥៣ៈ ngocedaw.pnh@gmail.com
អាសយដ្ឋានៈ ផ្ទះលេខ ១៦, ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ ប្រទេសកម្ពុជា ។
គេហទំព័រៈ www.ngocedaw.org
ហ្វេសបុកៈ https://www.facebook.com/TheCambodianNgoCommitteeOnCedaw

# មាតិកា


របាយការណ៍តាមដានអនុសញ្ញា ស៊ី ដ នៅប្រទេសកម្ពុជាឆ្នាំ២០១៧ ............ III

បញ្ជីពាក្យបំព្រួញនិងសទ្ទានុក្រម ............ III

សេចក្តីសង្ខេប ............ 1

ទិដ្ឋភាពទូទៅនៃបរិបទផ្លូវច្បាប់បច្ចុប្បន្ន ............ 1

ការប្រមូលទិន្នន័យសម្រាប់របាយការណ៍នេះ ............ 2

ការរៀបចំរបាយការណ៍នេះ............ 3

មាត្រា១: និយមន័យនៃការរើសអើង ............ 3

មាត្រា២: កាតព្វកិច្ចរបស់រដ្ឋ ............ 4

ការទទួលបានយុត្តិធម៌ ............ 4

ស្ត្រីក្នុងពន្ធនាគារ ............ 5

មាត្រា៣: សមភាពរបស់ស្ត្រីលើគ្រប់វិស័យ ............ 7

មាត្រា៤: វិធានការពិសេសបណ្តោះអាសន្ន ដើម្បីលើកកំពស់ស្ត្រី ............ 8

មាត្រា៥: ផ្នត់គំនិតយេនឌ័រ ............ 9

មាត្រា៦: ការជួញដូរ និងអាជីវកម្មផ្លូវភេទ ............ 11

មាត្រា៧: ឧបសគ្គចំពោះការចូលរួមក្នុងនយោបាយ និងជីវភាពសាធារណៈ ............ 12

មាត្រា៨: ការធានាបាននូវភាពជាតំណាងរបស់ស្ត្រីនៅលើឆាកអន្តរជាតិ ............ 15

មាត្រា៩: សញ្ជាតិ ............ 15

មាត្រា១០: ការអប់រំចំណេះដឹងទូទៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈ............ 16

មាត្រា១១: សិទ្ធិការងារ ............ 17

មាត្រា១២: ការទទួលបានការថែទាំសុខភាព ............ 19

មាត្រា១៣: ផលប្រយោជន៍ចំពោះការចូលរួមផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ............ 20

មាត្រា១៤: ស្ត្រីជនបទ ............ 21

មាត្រា១៥:សមត្ថភាពផ្លូវច្បាប់ ............ 22

មាត្រា១៦: សិទ្ធិអាពាហ៍ពិពាហ៍ ............ 23

Appendix: Members of NGO-CEDAW ............ 24

## របាយការណ៍តាមដានអនុសញ្ញា ស៊ី ដ សម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៧

### បញ្ជីពាក្យបំព្រួញនិងសទ្ទានុក្រម

| | |
|---|---|
| Bangkok Rules | វិធានអង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តិទៅលើស្ត្រីជាប់ពន្ធនាគារ និងវិធានការមិនឃុំខ្លួនទៅលើជនល្មើសជាស្ត្រី |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់ រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ |
| CHRC | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| CMDG | គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា |
| CRC | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ |
| CSO | អង្គការសង្គមស៊ីវិល |
| GBV | អំពើហិង្សាផ្អែកលើយេនឌ័រ |
| ICCPR | កតិការសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| LANGO | ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល |
| LEMNA | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ |
| LGBTQI | អ្នកស្រលាញ់ភេទដូចគ្នា |
| MoWA | ក្រសួងកិច្ចការនារី |
| NAPPVAW2 | ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) |
| Neary Rattanak IV | ផែនការជាតិដើម្បីសម្រេចឲ្យបានសមភាពយេនឌ័រ |
| NEC | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NGO-CEDAW | គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់ រាល់ទំរង់នៃការរើសអើងលើស្រីភេទ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| Prakas | ប្រកាស |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| STD | ជំងឺកាមរោគ |
| VAW | អំពើហិង្សាលើស្ត្រី |

## សេចក្តីសង្ខេប

២០១៧ គឺជាខួបទី ២៥ ដែលប្រទេសកម្ពុជាផ្តល់សច្ចាប័នទៅលើអនុសញ្ញាស៊ីដ ប៉ុន្តែនៅមានការប្រឈមជាមូលដ្ឋានជាច្រើន ដើម្បីសម្រេចឲ្យបាននូវសមភាពពិតប្រាកដរវាងបុរសនិងស្ត្រី។គម្រូបែបផែនដែលមានលក្ខណៈស៊ីសង្វាក់គ្នាមួយពាសពេញគ្រប់វិស័យ និងផ្នែកនានានៅក្នុងសង្គមគឺផ្ទត់គំនិតខុសឆ្គងលើយេនឌ័រនៅតែបន្តមាន។ ជំនឿដ៏មានៈដែលថាស្ត្រីមានសមត្ថភាពអន់ជាងបុរស និងការរំពឹងថាស្ត្រីត្រូវសម្របខ្លួនទៅតាមតួនាទីតាមបែបប្រពៃណីនៅក្នុងគ្រួសារនោះបានដើរតួនាទីជាឧបសគ្គដល់ការរីកចម្រើននៅក្នុងការអនុវត្តរាល់មាត្រានៃអនុសញ្ញាស៊ីដ។ ឥរិយាបទទាំងនេះនៅប្រកាន់ភ្ជាប់ដោយបុរស និងស្ត្រីនិយោជកក្នុងវិស័យឯកជននិងសាធារណៈអ្នកអប់រំ អ្នកវិជ្ជាជីវៈក្នុងវិស័យសុខាភិបាល មន្ត្រីអនុវត្តច្បាប់ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ គម្រូបែបផែនមួយទៀតគឺការស្វែងយល់របស់រដ្ឋាភិបាលអំពីសមភាព គឺត្រឹមតែជាគោលដៅទូទៅនៃសមភាពបែបផ្លូវការ ជាជាងការយល់ថានេះជាកាតព្វកិច្ចក្នុងការសម្រេចឲ្យបាន សមភាពពិតប្រាកដនៅក្នុងគ្រប់វិស័យឲ្យបានឆាប់តាមដែលអាចធ្វើទៅបានតាមរយៈវិធានការពិសេសបណ្តោះអាសន្ន ដោយរួមបញ្ចូលទាំងប្រព័ន្ធកូតាជាដើម។សមាជិករបស់អង្គការNGO-CEDAWសូមធ្វើការកោតសរសើរចំពោះរដ្ឋាភិបាលកម្ពុជាក្នុងការអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការរៀបចំបង្កើតផែនការសកម្មភាពជាតិក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចសហប្រតិបត្តិការក្នុងការពិចារណាទៅលើការធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីធានាឲ្យច្បាប់នេះអនុលោមតាមអនុសញ្ញាស៊ីដ។ ក៏ប៉ុន្តែ យើងនៅមានការព្រួយបារម្ភថាថវិកា និងធនធានសម្រាប់អនុវត្តផែនការទាំងនេះពឹងផ្អែកខ្លាំងពេកទៅលើជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងជំនួយអន្តរជាតិ ។ ខណៈដែលសេដ្ឋកិច្ចប្រទេសកម្ពុជា មានភាពរឹងមាំ និងបន្តកើនឡើងក្នុង អាត្រា៧%ក្នុងមួយឆ្នាំនោះ[1] ហើយជំនួយបរទេសកំពុងមានការធ្លាក់ចុះ។ ទឹកប្រាក់បន្ថែមចំនួន ៧០០.០០០ ដុល្លារអាមេរិកដែលត្រូវ ការពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីបង្កើតកម្មវិធីនានា ផ្តោតទៅលើការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព[2] ។
រាជរដ្ឋាភិបាលកម្ពុជាគឺចាំបាច់ក្នុងការបង្កើនតួនាទីរបស់ខ្លួនឲ្យបានខ្លាំងបន្ថែមទៀត ប្រសិនបើចង់សម្រេចឲ្យបាននូវការរីកចម្រើននៅក្នុងបរិយាកាសមួយដែលឥទ្ធិពលរបស់អង្គការមិនមែនរដ្ឋាភិបាលកាន់តែមានសភាពរួញតូចទៅនោះ។

## ទិដ្ឋភាពទូទៅនៃបរិបទផ្លូវច្បាប់បច្ចុប្បន្ន

រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាមាត្រា៣១យោងដោយផ្ទាល់ចំពោះប្រទេសកម្ពុជា ក្នុងការគោរពសិទ្ធិមនុស្សជា សាកលដោយរាប់បញ្ចូលទាំងអនុសញ្ញានានាស្តីពីសិទ្ធិស្ត្រីនិងសិទ្ធិកុមារ[3]។ រដ្ឋាភិបាលបានបង្កើតអោយមាន គណៈកម្មាធិការ សិទ្ធិមនុស្សកម្ពុជា សម្រាប់ប្រតិបត្តិការក្នុងការលើកកម្ពស់សិទ្ធិទាំងនេះ។ ក៏ប៉ុន្តែ នៅក្នុងសន្និសីទស្តីពីសិទ្ធិមនុស្សក្នុង ឆ្នាំ២០១៧ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានបញ្ជាក់ថា សិទ្ធិទាំងអស់នៅក្នុងរដ្ឋធម្មនុញ្ញ ត្រូវអនុលោមទៅតាមច្បាប់[4] ហើយ គណបក្សកាន់អំណាចអាចអនុម័តច្បាប់ទាំងឡាយណាដែលគណបក្សនេះចង់បាន រហូតដល់ពេលដែលគណបក្សនេះត្រូវ បានគេបោះឆ្នោតទម្លាក់ឈប់ឲ្យកាន់អំណាច[5]។ច្បាប់ថ្មីនានាដែលមានការរឹតត្បិតទៅលើមាត្រា៣១ត្រូវបានអនុម័តក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

ក្នុងឆ្នាំ២០១៥ រដ្ឋាភិបាលកម្ពុជា បានអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ដែលបង្កើតនូវការរឹតត្បឹតថ្មីៗទៀតទៅលើអង្គការមិនស្វែងរកប្រាក់ចំណេញ និងបានកំណត់ឲ្យ ក្រុមមនុស្សនានាដែលចង់ជួបជុំប្រមូលផ្តុំគ្នាត្រូវតែចុះបញ្ជីជាដាច់ខាត (ដោយត្រូវមានអាស័យដ្ឋានការិយាល័យជាផ្លូវការ និងមានលក្ខន្តិកៈជាលាយលក្ខណ៍អក្សរ)[6] ។ ពីឆ្នាំ២០១៥ ដល់ ២០១៧ ច្បាប់បោះឆ្នោតសំខាន់ៗទាំងអស់ត្រូវបានធ្វើវិសោធនកម្ម ហើយមានច្បាប់ខ្លះ ត្រូវបានធ្វើវិសោធនកម្មជាច្រើនដង។ជាពិសេសប្រទេសកម្ពុជាបានធ្វើវិសោធនកម្មច្បាប់ស្តីពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតឃុំសង្កាត់ និងច្បាប់ស្តីពីគណបក្សនយោបាយ។

ក្នុងខែមិថុនា ឆ្នាំ២០១៧ ការបោះឆ្នោតត្រូវបានរៀបចំឡើងសម្រាប់តំណែងក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ហើយអ្នកបោះឆ្នោតចំនួនជិត ៥០% បានបោះឆ្នោតឲ្យគណបក្សដ៏ទៃទៀតក្រៅពីគណបក្សកាន់អំណាច ដោយក្នុងនោះមាន ៤៣% បានបោះឆ្នោតឲ្យគណបក្សប្រឆាំង ។បន្ទាប់ពីការបោះឆ្នោតមេដឹកនាំគណបក្សប្រឆាំងត្រូវបានចាប់ដាក់ពន្ធនាគារហើយរដ្ឋាភិបាល

1 ការសង្ខេបអំពីកំណើន GDP ឆ្នាំ ២០១៧ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គេហទំព័រ met.gov.kh
2 ព័ត៌មានផ្តល់នៅក្នុងវេទិការអន្តរជាតិនៃអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ។
3 សម្រាប់អត្ថបទពេញលេញជាភាសាអង់គ្លេសនៃច្បាប់ជាច្រើនដែលដកស្រង់មកប្រើក្នុងរបាយការណ៍នេះ សូមមើល www.ngocedaw.org/library/cambodian-law.
4 ឧទាហរណ៍ កថាខណ្ឌទីមួយនៃមាត្រា៤២នៃរដ្ឋធម្មនុញ្ញចែងថា “ពលរដ្ឋគ្រប់រូប មានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះមានកំណត់ដោយច្បាប់”។
5 សន្និសីទស្តីពី “សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន” នៅថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៧ នៅសណ្ឋាគារសាន់វ៉េ ដែលរៀបចំដោយ OHCHR ដោយមានកិច្ចសហការជាមួយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រោមការគាំទ្ររបស់ស្ថានទូតកាណាដាក្នុងទីក្រុងបាងកក។ លោក កែវ រ៉េមី ថ្លែងជាភាសាខ្មែរ និងតាមការបកប្រែផ្ទាល់ជាភាសាអង់គ្លេសដោយអ្នករៀបចំរបាយការណ៍នេះ។
6 ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មាត្រា៥, ៦ និង៧ រៀបរាប់អំពីលក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជី។ ការចុះបញ្ជីពីមុនៗ មានគ្របដណ្តប់ដោយក្រម រដ្ឋប្បវេណី និងមិនមែនជាកាតព្វកិច្ចដាច់ខាតនោះទេ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល មាត្រា៩ ហាមឃាត់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជីមិនឲ្យធ្វើសកម្មភាពទេ។

បានប្រកាសថា គណបក្សប្រឆាំងជាអង្គការភេវរកម្ម តាមការចោទប្រកាន់ថាមានការឃុប ឃិតជាមួយ សហរដ្ឋអាមេរិក ក្នុងការលើកកម្ពស់ប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ដែលរដ្ឋាភិបាលបានចាត់ទុកថាជា "បដិវត្តន៍ពណ៌"[7] ។ មានការ ដាក់ញត្តិប្តឹងទៅតុលាការស្នើសុំឲ្យរំលាយគណបក្សប្រឆាំង ហើយច្បាប់ទាក់ទងនឹងការបោះឆ្នោតត្រូវបានធ្វើវិសោធនកម្មដើម្បី អនុញ្ញាតឲ្យមានការបែងចែកអាសនៈដែលគណបក្សប្រឆាំងទទួលបាន ដោយភាគច្រើនបានទៅលើគណបក្សកាន់អំណាច។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្តត្រូវបានធ្វើវិសោធនកម្មដើម្បីបែងចែងអាសនៈថ្នាក់ជាតិរបស់គណបក្សប្រឆាំងដល់គណបក្សតូចៗដែលមិនបានទទួលចំនួនសន្លឹកឆ្នោតច្រើនគ្រប់គ្រាន់នៅក្នុងការបោះឆ្នោតថ្នាក់ជាតិឬថ្នាក់មូលដ្ឋាន។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ជាថ្ងៃដែលតុលាការសម្រេចរំលាយគណបក្សប្រឆាំងដ៏សំខាន់នោះរដ្ឋាភិបាលបានហាមឃាត់រាល់ការធ្វើបាតុកម្មដោយក្រុមឬបុគ្គលនានា និងរារាំងបុគ្គលនានាមិនឲ្យធ្វើដំណើរពីតាមខេត្តចូលមករាជធានីឡើយ ប្រសិនបើអាជ្ញាធរសង្ស័យថាពួកគេអាចនឹងមកប្រឆាំងតវ៉ានឹងសេចក្តីសម្រេចរបស់តុលាការ។ ផ្លូវធ្វើដំណើរមួយចំនួនស្ទើរពាសពេញទីក្រុងត្រូវបានបិទ ដើម្បីបង្ការការធ្វើបាតុកម្មណាមួយ។ ចៅក្រមដែលចេញសេចក្តីសម្រេចក្នុងការរំលាយ គណបក្សប្រឆាំង គឺជាសមាជិកជាន់ខ្ពស់បំផុតទី១៥ របស់គណបក្សកាន់អំណាច។

រយៈពេលចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ២០១៨បានប្រព្រឹត្តិទៅពីខែកញ្ញាដល់ដើមខែវិច្ឆិកាឆ្នាំ២០១៧។ នៅមុននិងនៅក្នុងរយៈពេលនេះ ស្ថានីយ៍វិទ្យុឯករាជ្យ និងអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រលទ្ធិប្រជាធិបតេយ្យមានមូលដ្ឋាននៅសហរដ្ឋអាមេរិចជាច្រើនត្រូវបានបិទ។ សារព័ត៌មានផ្សាយជាពីរភាសាដ៏ធំមួយត្រូវបានបិទបន្ទាប់ពីរដ្ឋាភិបាលបានចោទប្រកាន់ថា ពួកគេបានជំពាក់ប្រាក់ពន្ធជាច្រើនលានដុល្លារ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មួយចំនួនបានរាយការណ៍ថា ពួកគេត្រូវបានបញ្ឈប់មិនឲ្យរៀបចំកិច្ចប្រជុំជាមួយសហគមន៍គោលដៅរបស់ពួកគេ ឬធ្វើសកម្មភាពអប់រំដល់អ្នកបោះឆ្នោតឡើយនៅក្នុងឆ្នាំ២០១៧។ បរិបទផ្លូវច្បាប់ខាងលើនេះ បង្ហាញថា អនុសញ្ញាស៊ីដមិនទាន់បញ្ចូលពេញលេញទៅក្នុងប្រព័ន្ធច្បាប់ជាតិនៅឡើយទេ។

## ការប្រមូលទិន្នន័យសម្រាប់របាយការណ៍នេះ

ទិន្នន័យភាគច្រើនដែលប្រើក្នុងរបាយការណ៍នេះបានទទួលពីការប្រើប្រាស់ឧបករណ៍តាមដានរបស់អង្គការ NGO-CEDAW។ ឧបករណ៍នេះ រួមមាន ការណែនាំអំពីការប្រមូលភស្តុតាង និងសំណួរនានាដែលបានបង្កើតឡើង ដើម្បីប្រមូលព័ត៌មានដែលទាក់ទងទៅនឹងមាត្រាជាក់លាក់ក្នុងអនុសញ្ញា និងភ្ជាប់ទៅនឹងប្រធានបទសំខាន់ៗចំនួន១៥ ទាក់ទងនឹងសិទ្ធិរបស់ស្រ្តី។ អង្គការ NGO-CEDAW បានធ្វើការបណ្តុះបណ្តាលជាច្រើនអំពីការប្រើប្រាស់ឧបករណ៍នេះដល់បុគ្គលិកនិងអង្គការសមាជិកអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ឧបករណ៍នេះត្រូវបានចម្រាញ់ដោយផ្អែកតាមបទពិសោធន៍និងការស្នើរបស់អង្គការសមាជិក។ ឧបករណ៍ចុងក្រោយត្រូវបាន ប្រើប្រាស់ក្នុងឆ្នាំ២០១៧ដោយអង្គការ NGO-CEDAW , អង្គការសមាជិកចំនួន៣៧ និងបណ្តាញដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើការស្ទង់មតិលម្អិតអំពីបញ្ហាប្រឈមនានាដែលស្រ្តីក្នុងប្រទេសកម្ពុជាបានជួបប្រទះនិងអំពី មធ្យោបាយជាសក្តានុពលក្នុងការកាត់បន្ថយបញ្ហាប្រឈមទាំងនោះ។អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដែលមិនមែនជាសមាជិក NGO- CEDAW និងស្ថាប័នរដ្ឋាភិបាលមួយចំនួនក៏ត្រូវបានសម្ភាសន៍សម្រាប់ការរៀបចំរបាយការណ៍នេះដែរ។

ទិន្នន័យបន្ថែម ត្រូវបានទទួលតាមរយៈ៖

ក) ការស្រាវជ្រាវដោយអង្គការ NGO-CEDAW និងសមាជិក

ខ) ការពិនិត្យលើរបាយការណ៍ដែលបានបោះពុម្ពផ្សាយពីអង្គការផ្សេងៗទៀត

គ) ស្ថិតិរដ្ឋាភិបាល ច្បាប់ ផែនការ, និង

ឃ) ការពិនិត្យទៅលើការផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យទៅលើបញ្ហាសំខាន់ៗដែលប៉ះពាល់ដល់ស្រ្តីនៅក្នុងប្រទេសកម្ពុជា

ង) ស្ថិតិនិងព័ត៌មានផ្សេងទៀតដែលផ្តល់ដោយ រដ្ឋាភិបាលកម្ពុជាតាមរយៈបទបង្ហាញអំពីរបាយការណ៍ព្រាងរបស់រដ្ឋាភិបាលសម្រាប់ដាក់ជូនគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកលើអនុសញ្ញា ស៊ីដ កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧។

ចុងក្រោយអង្គការ NGO-CEDAW បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់សមាជិកសង្គមស៊ីវិលនៅក្នុងខែវិច្ឆិកាឆ្នាំ២០១៧ ដែលបានចូលរួមដោយសិស្ស/និស្សិត ជនពិការ អ្នកស្រលាញ់ភេទដូចគ្នា និងអ្នកស្ម័គ្រចិត្ត/បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ អ្នកចូលរួមបានធ្វើការជាក្រុម ដើម្បីវាយតម្លៃទៅលើរបាយការណ៍ព្រាងនេះ និងស្នើឲ្យមានការដាក់បញ្ចូលបញ្ហា បន្ថែមផ្សេងទៀតទៅក្នុងរបាយការណ៍។

7 ឯកសារបង្រៀនរបស់ប៉ូលីសជាតិ ដែលបានផ្សព្វផ្សាយដោយសារព័ត៌មាននៅក្នុងឆ្នាំ២០១៧ បានរាយបញ្ជីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល/សមាគមជាតិ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនឯកជនមួយចំនួនធំថាបានជាប់ទាក់ទងក្នុងការរៀបចំ "បដិវត្តន៍ព័ណ" ។" មៀច ដារា និងអាណាន់ បាលីហ្កា " ធនាគារ ក្រុមហ៊ុនឯកជន និង ស្ថាប័នមេក្រូហិរញ្ញវត្ថុមួយចំនួន ត្រូវបានសង្ស័យបានជាប់ពាក់ព័ន្ធនឹង "បដិវត្តន៍ព័ណ" ថ្ងៃ ២៤ ខែ តុលា ឆ្នាំ ២០១៧ ភ្នំពេញប៉ុស្ត៍ ។ http://m.phnompenhpost.com/national/banks-businesses-and-mfis-latest-suspects-colour-revolution

## ការរៀបចំរបាយការណ៍នេះ

តួរបាយការណ៍នេះ ត្រូវរៀបចំឡើងតាមមាត្រានៃអនុសញ្ញា ស៊ី ដ។ បញ្ហាពាក់ព័ន្ធមួយចំនួនដោយរាប់បញ្ចូលទាំងបញ្ហាអំពើហិង្សាលើយេនឌ័រ ការទទួលបានយុត្តិធម៌ សិទ្ធិដីធ្លី និងបរិស្ថាន គ្របដណ្តប់លើចំនួនច្រើនជាងមួយមាត្រា។ បញ្ហាទាំងនេះដាក់បញ្ចូលនៅក្នុងផ្នែកដែលមានជាប់ទាក់ទងបំផុតទៅនឹងប្រធានបទដែលបានពិភាក្សា។ ឧទាហរណ៍ដោយសារតែឧបសគ្គសំខាន់ៗដែលរារាំងការរីកចម្រើន ចំពោះការកាត់បន្ថយអំពើហិង្សាលើយេនឌ័រ គឺជាឥរិយាបថវប្បធម៌ដែលបានចាក់ឫសយ៉ាងជ្រៅ អំពីហិង្សាលើយេនឌ័រនោះ ប្រធានបទនេះ ត្រូវបានលើកឡើងជាចម្បងក្រោមមាត្រា៥។

## មាត្រា 1

## និយមន័យនៃការរើសអើង គឺជា “ការបែងចែក ការផាត់ចេញ ការរឹតត្បិតផ្អែកលើភេទដែលមាន បំណង ឬអនុភាពធ្វើឲ្យមោឃៈភាព ឬខូចខាតនូវការទទួលស្គាល់ ការអាស្រ័យផល និងការប្រើប្រាស់ដោយស្ត្រីទៅលើសិទ្ធិទាំងអស់ ”។

នេះ ជាការល្អណាស់ ដែលរដ្ឋាភិបាលកម្ពុជាបានស្ម័គ្រចិត្តទទួលយកនូវកាតព្វកិច្ច នៅក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនុច ៥៖(បញ្ចប់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីនិងក្មេងស្រីទាំងអស់នៅគ្រប់កន្លែង)នៅត្រឹមឆ្នាំ ២០៣០ ។ ទោះបីជារដ្ឋធម្មនុញ្ញនិងច្បាប់ជាច្រើន ហាមឃាត់ការរើសអើងដោយសារមូលហេតុភេទក៏ដោយក៏មិនមានច្បាប់ណាមួយក្នុងប្រទេសកម្ពុជា បានដាក់បញ្ចូលនូវនិយមន័យអំពីការរើសអើង ដែលមានភាពស៊ីសង្វាក់ជាមួយនឹងគោលដៅនៃសមភាពពិតប្រាកដ ដូចមានចែងនៅក្នុងអនុសញ្ញា ស៊ីដ នោះទេ។ភាគច្រើននៃច្បាប់ទាំងនេះអនុលោមតាមទម្រង់នៃសមភាពជាផ្លូវការ ដែលមានគោលបំណងប្រព្រឹត្តទៅលើបុរសនិងស្ត្រីស្មើគ្នា ដោយគ្មាននិយមន័យឬយុទ្ធសាស្ត្រលម្អិតណាមួយ សម្រាប់ទប់ស្កាត់ការរើសអើងបែបនេះ និងមិនមានការទទួលស្គាល់ថា ស្ត្រីគឺជាគោលដៅនៃការរើសអើងបែបនេះជាទូទៅនោះទេ។ ឧទាហរណ៍ ក្រមព្រហ្មទណ្ឌ មាត្រា២៦៥-២៧៣ ហាមឃាត់ការបដិសេធក្នុងការលក់ទំនិញ ឬការផ្តល់ ឬការបដិសេធមិនផ្តល់ការងារ ដោយសារមូលហេតុភេទ និងហេតុផលដទៃទៀត។ ច្បាប់ផ្សេងទៀត ចាប់យកវិធីសាស្ត្រការពារនិយមចំពោះស្ត្រីដូចជាការរឹតត្បិតលើការរៀបអាពាហ៍ពិពាហ៍ទៅលើស្ត្រីតែមិនបានរឹតត្បិតទៅលើបុរសទេ។ឧទាហរណ៍ ក្រមរដ្ឋប្បវេណី មាត្រា៩៥០ចែងអំពីការហាមស្ត្រីមិនឲ្យរៀបអាពាហ៍ពិពាហ៍ ឡើងវិញក្នុង រយៈពេល១២០ថ្ងៃ ក្រោយពេលលែងលះគ្នា។ច្បាប់នេះហាក់ដូចជាហួសសម័យទៅហើយដោយសារតែច្បាប់នេះ ពឹងផ្អែកទៅលើផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រដោយមិនមានវិធីអ្វីផ្សេងក្នុងការកំណត់នរណាជាឪពុក។[8]

បន្ថែមលើនេះ ក្រសួងការបរទេសបានចេញកំណត់ទូតមួយក្នុងឆ្នាំ២០១១ដែលមានការរើសអើងទៅលើស្ត្រីតាមរយៈការខិតខំប្រឹងប្រែងដើម្បីការពារស្ត្រីទៅវិញ។កំណត់ទូតនោះហាមឃាត់មិនឲ្យស្ត្រីកម្ពុជារៀបការជាមួយបុរសបរទេសដែលមានអាយុលើសពី៥០ឆ្នាំ ឬដែលមានចំណូលក្រោម $២.៥០០ ក្នុងមួយខែ (ចំនួននេះ ខ្ពស់ជាងប្រាក់ខែធម្មតានៅក្នុងប្រទេស កម្ពុជាខ្លាំងណាស់) គឺអ្នកដែលមិនមានប្រាក់ខែខ្ពស់។ វិធាននេះមិនអនុវត្តទៅលើស្ត្រីបរទេសដែលចង់រៀបការជាមួយ នឹងបុរសកម្ពុជានោះទេ។ មិនមានការលើកលែងណាមួយក្នុងករណីថាតើវាមានភស្តុតាងអំពីទំនាក់ទំនងពិតប្រាកដ ឬថាតើស្ត្រីមានប្រាក់ចំណូលខ្ពស់ហើយ ថាតើស្ត្រីនោះមានអាយុ៥០ឆ្នាំ ឬលើស៥០ឆ្នាំនោះទេ។

៨ ច្បាប់នេះមិនមានចេតនាក្នុងការការពារបុរស ដែលអាចចប់ពន្យារការរៀបការឡើងវិញ ប្រសិនបើពួកគេបានរកឃើញថា បុរសទាំងនោះជាឪពុករបស់កូន ដែលនេះជាការស្នើឡើងបន្ថែមទៀតថា ច្បាប់នេះ ពឹងទៅលើផ្នត់គំនិតខុសឆ្គងផ្អែកយេនឌ័រ អំពីតួនាទីបុរសនិងស្ត្រីនៅក្នុងគ្រួសារ។

# មាត្រា 2

## កាតព្វកិច្ចរបស់រដ្ឋក្នុងការបង្កើតគោលនយោបាយ ច្បាប់ និងចាត់វិធានការដែលសមស្របទាំងអស់ដើម្បីលុបបំបាត់ការរើសអើង។

## ការទទួលបានយុត្តិធម៌

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការបណ្តុះបណ្តាលគ្រប់កម្រិតនៃប្រព័ន្ធយុត្តិធម៌ និងបង្កើតគោលនយោបាយ នានាដែលទទួលស្គាល់សារៈសំខាន់នៃការទទួលបានយុត្តិធម៌។ តែទោះបែបនេះក្តី មានយន្តការផ្លូវច្បាប់តិចតួចបំផុតដែលអាចរកបានសម្រាប់ស្ត្រីដែលប្រឈមនឹងការរើសអើង។ ប្រព័ន្ធតុលាការ ជាប្រព័ន្ធមិនអាចទុកចិត្តបានចំពោះមនុស្សជាច្រើនហើយជារឿយៗស្ត្រីភាគច្រើនមិនអាចទទួលបានយុត្តិធម៌ទេ ជាពិសេសស្ត្រីនៅតាមជនបទ ដោយសារតែមូលហេតុជាច្រើន។ ១) អាជ្ញាធរមូលដ្ឋានភាគច្រើនបន្តបង្អាក់ទឹកចិត្តក្នុងការដាក់បណ្តឹងផ្លូវការដោយគាំទ្រការសម្រុះសម្រួល ឬដំណោះស្រាយក្រៅផ្លូវការ ដែលអាជ្ញាធរមូលដ្ឋាន ឬសូម្បីតែសមាជិកគ្រួសារបែរជាអ្នកដែលគិតគូរអំពីដំណោះស្រាយជំនួសឲ្យគូរភាគីទៅវិញ។ ២)មានមេធាវីចំនួនតិចតួចនៅទូទាំងប្រទេស ហើយជំនួយផ្នែកច្បាប់ដែលអាចរកបានមានចំនួនតិចតួចណាស់។ ទោះបីជាមានការកើនឡើងបន្តិចបន្តួចទៅលើថវិកាជំនួយផ្នែកច្បាប់ និងចំនួនមេធាវីក៏ដោយ ក៏មាន សមាមាត្រត្រឹមតែមេធាវីម្នាក់សម្រាប់ប្រជាជន ១៥.០០០ នាក់ប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជា[9]។ ចំនួនអ្នកឯកទេសវិកលចរិត និងអ្នកចិត្តសាស្ត្រ ក៏មានការខ្វះខាតដែរសម្រាប់ប្រទេសនេះដែលប្រការនេះមានសារៈសំខាន់ជាពិសេសសម្រាប់ជនរងគ្រោះដែល ជារឿយៗត្រូវការការព្យាបាលបញ្ហាចប់បារម្ភឬការតានតឹងក្នុងចិត្តក្រោយមានការប៉ះទង្គិចផ្លូវចិត្តនោះ។

កំណត់ត្រានិងស្ថិតិតុលាការ នៅតែមិនទាន់អាចរកបាននៅឡើយ។ ខណៈដែលក្រសួងយុត្តិធម៌បានចាប់ផ្តើមដំណើរការបញ្ចូលប្រព័ន្ធកំណត់ត្រាតុលាការតាមកុំព្យូទ័រ ការប្រាស្រ័យទាក់ទងក្នុងចំណោមតុលាការ និងនាយកដ្ឋាននានា នៅមិនទាន់ល្អនៅឡើយទេ ហើយតម្លាភាពទាក់ទងនឹងចំនួន និងលទ្ធផលនៃសំណុំរឿងនៅតុលាការនៅមានកម្រិតតិចតួចនៅឡើយ ជាពិសេសទាក់ទង នឹងសំណុំរឿងអំពើហិង្សាក្នុងគ្រួសារ។ កំណត់ត្រាភាគច្រើនមិនត្រូវបានបញ្ចេញ ឲ្យដឹងសម្រាប់សំណុំរឿងទាំងនេះ ទេសូម្បីតែបន្ទាប់ពីមានការលុបឈ្មោះ និងព័ត៌មាននានាដែលបង្ហាញពីអត្តសញ្ញាណផ្សេងទៀតហើយក៏ដោយ។ ជាងនេះទៅទៀត ដោយសារតែអំពើហិង្សាក្នុងគ្រួសារ មិនមែនជា បទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកវាជាការលំបាកក្នុងការ ប្រើប្រាស់ស្ថិតិដែលផ្អែកទៅលើការចោទប្រកាន់ព្រហ្មទណ្ឌ តែមួយមុខក្នុងការបែងចែករវាងអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សារវាង ជនមិនស្គាល់គ្នា។

ជាទូទៅ កំណែទម្រង់និងប្រព័ន្ធច្បាប់ ក្នុងការនាំឲ្យប្រទេស កម្ពុជាអនុលោមតាមអនុសាសន៍ទូទៅ លេខ៣៣ មិនទាន់ត្រូវបាន គេយកមកអនុវត្តនៅឡើយទេ។ របាយការណ៍ឆ្នាំ២០១៧ ដោយគណៈកម្មាធិការចៅក្រមអន្តរជាតិ បានសង្ខេបការស្រាវជ្រាវដែលលាតត្រដាង អំពីការខ្វះខាតទាំងស្រុងនៅគ្រប់ដំណាក់កាលទាំងអស់នៃប្រព័ន្ធច្បាប់នៅក្នុង ប្រទេសកម្ពុជា។ រាប់ចាប់តាំងពីការខ្វះខាត ជំនួយផ្នែកច្បាប់ អំពើពុករលួយ (រួមទាំងការសូកប៉ាន់ប៉ូលីសទទួលបានចំណែកលុយកាត់ចេញពីដំណោះស្រាយដល់ចៅក្រម និងព្រះរាជអាជ្ញាដែលមានភាពលម្អៀង) ដល់ការខ្វះខាតដំណោះស្រាយប្រកបដោយអត្ថន័យពេញលេញ នៅក្នុងប្រព័ន្ធតុលាការនោះ ប្រទេសកម្ពុជាបន្តខ្វះខាតនីតិរដ្ឋពិតប្រាកដ[10] ។តាមពិតទៅនៅក្នុងឆ្នាំ២០១៦ ប្រទេសកម្ពុជាទទួលបាន ចំណាត់ថ្នាក់លេខ ១១២ ក្នុងចំណោម ប្រទេសចំនួន ១១៣ នៅក្នុង លិបិក្រមនីតិ រដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក[11] ។

ឧទាហរណ៍មួយ នៃអំពើពុករលួយនៅក្នុងប្រព័ន្ធផ្លូវច្បាប់គឺភាពបរាជ័យក្នុងការទប់ស្កាត់ការបង់កម្រៃក្រៅសេវា តុលាការ និងការសូកប៉ាន់ជាលក្ខណៈប្រព័ន្ធ [12]។ ករណីស្ត្រីម្នាក់ស្វែងរកយុត្តិធម៌ដោយសារការរំលោភសេពសន្ថវៈ ដំបូងនាងត្រូវស្វែងរកជំនួយពីអាជ្ញាធរ ឬបុគ្គលិកមន្ទីរពេទ្យដែលពួកគេបានសើចចំអកដល់នាងចំពោះរឿងដែលបានកើតឡើងនោះទៅវិញ។ នាងត្រូវការឧបករណ៍ធ្វើតេស្តិ៍អំពីការរំលោភសេពសន្ថវៈដែលគួរតែមិនបាច់បង់កម្រៃ និងអាចរកបាន ប៉ុន្តែនៅកន្លែងខ្លះ នាងត្រូវបង់លុយ $២៥ ហើយ

9 រាជរដ្ឋាភិបាលកម្ពុជាសេចក្តីព្រាងរបាយការណ៍រដ្ឋភាគីទៅគណៈកម្មាធិការអនុសញ្ញាស៊ី ដ ឆ្នាំ២០១៧ បង្ហាញថាប្រជាជនសរុបគឺ ១៥.៥លាននាក់ក្នុងឆ្នាំ២០១៦ និងមានមេធាវីសរុបចំនួន១០១១នាក់ដែលបានចុះបញ្ជីនៅគណៈមេធាវីព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១៧។

10 គណៈកម្មាធិការចៅក្រមអន្តរជាតិ "ការសិក្សា (Baseline study) អំពីការទទួលបានយុត្តិធម៌សម្រាប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា" ខែតុលា ឆ្នាំ២០១៧

11 http://data.worldjusticeproject.org/. ការសិក្សានេះ មិនបានផ្តល់លំដាប់ថ្នាក់ទៅលើប្រទេសជាច្រើន ដោយរួមមានទាំងប្រទេសនៅក្នុងទ្វីបអាហ្វ្រិកនិងមជ្ឈិមបូព៌ាដែលកំពុងមានសង្គ្រាមស៊ីវិល ។

12 ការស្រាវស្រាវដោយប្រើឧបករណ៍តាមដាន ពីអង្គការ RHAC អង្គការដែលផ្តល់សេវាកម្មផ្លូវច្បាប់ និងសង្គមដល់ជនរងគ្រោះដោយអំពើហិង្សាផ្អែកលើភេទ ។

កន្លែងខ្លះទៀតមិនមានការផ្តត់ផ្គង់សម្ភារៈនេះទេ [13]។ ចំពោះករណីខ្លះទៀតជំហានបន្ទាប់មកអាជ្ញាធរអាចនឹងបដិសេធមិនធ្វើការចោទប្រកាន់តែផ្ទុយមកវិញអាចជំរុញឲ្យនាងរៀបការជាមួយជនល្មើស ឬទទួលសំណងជាលុយ ដោយលុយមួយផ្នែកនឹងបានទៅប៉ូលីស។ តាមរយៈការជួយជ្រោមជ្រែងពីអង្គការមិនមែនរដ្ឋាភិបាលមួយ នាងអាចដាក់ពាក្យបណ្តឹងទៅតុលាការ ប៉ុន្តែប្រាក់ប្រដាប់ក្តីតុលាការមិនត្រូវបានលើកលែងទេ។ ចៅក្រមទំនងជានឹងជំរុញឲ្យទទួលយកដំណោះស្រាយណាមួយ ដើម្បីទម្លាក់ការចោទប្រកាន់។ ដំណោះស្រាយនេះ អាចជាការបង់លុយដោយជនល្មើស ហើយលុយមួយចំណែកត្រូវបង់ទៅចៅក្រមនិងមេធាវីដែលត្រូវបានចាត់តាំងសម្រាប់ករណីនោះ។ ជនល្មើសប្រហែលគ្រាន់តែត្រូវសូកប៉ាន់ដើម្បីឲ្យប៉ូលីសបដិសេធមិនស្នើសុំដីកាជាការស្រេច។ ក្នុងករណីដែលមានការផ្តន្ទាទោស ជនល្មើសអាចទំនងជាទទួលបានការបន្ធូរបន្ថយទោសនិង ឬព្យួរទោសតែម្តងក៏មាន[14] ។

ជាងនេះទៀត ក្នុងករណីការរំលោភសេពសន្ថវៈទៅលើអនីតិជន គេដឹងថាអាជ្ញាធរមួយចំនួនជំរុញឲ្យមានដំណោះស្រាយ ដោយកែសំបុត្រកំណើតរបស់ជនរងគ្រោះ ដើម្បីធ្វើឲ្យកុមារមានអាយុច្រើន ។

## ស្រ្តីក្នុងពន្ធនាគារ

រាជរដ្ឋាភិបាលកម្ពុជា នៅចុងឆ្នាំ ២០១៦ និងក្នុងឆ្នាំ ២០១៧ បានលើកទឹកចិត្តក្នុងយុទ្ធនាការកម្រិតខ្ពស់មួយ ក្នុងការប្រឆាំងការជួញដូរ និងប្រើប្រាស់ថ្នាំញៀន ក្នុងប្រទេសកម្ពុជាដែលជាគុណសម្បត្តិក្នុងការធ្វើអោយសង្គម មានសុវត្ថិភាពល្អប្រសើរជាងមុន។ ទោះជាបែបនេះក្តី ជាលទ្ធផលចំពោះវិធីសាស្រ្តដែលបានប្រើនោះគឺធ្វើអោយ ចំនួនស្រ្តីនៅក្នុងពន្ធនាគារបានកើនឡើងគួរឲ្យកត់សម្គាល់[15]។

ជំនួសឲ្យការផ្តល់ជម្រើសក្នុងការ ព្យាបាលសំរាប់ស្រ្តីកម្ពុជាដែលប្រើប្រាស់ថ្នាំញៀន ជាញឹកញាប់រដ្ឋាភិបាលបញ្ជូនពួកគេទៅពន្ធនាគារដោយផ្ទាល់ទៅវិញ។

ពន្ធនាគារដែល មាន ភាពចង្អៀតណែនស្រាប់ហើយនេះ បានកើនឡើងយ៉ាងកំហុកក្នុងកម្រិត២០%បន្ថែមទៀត។ ការផ្ទុកចំនួនអ្នកជាប់ក្នុងពន្ធនាគារភាគច្រើន មានចំនួនលើស ពី២០០%[16]។ ការបារម្ភជាពិសេស គឺទាក់ទងនឹងចំនួនអ្នកជាប់ ឃុំបណ្តោះអាសន្នដែលមានកម្រិតខ្ពស់(1/3% នៃចំនួនអ្នកជាប់ក្នុងពន្ធនាគារសរុបទាំងបុរសនិងស្រ្តី[17]) ទោះបីជាមាននីតិវិធីជា លាយលក្ខណ៍អក្សរក្នុងគោលបំណងកាត់បន្ថយចំនួននេះក៏ ដោយដែលក្នុងនោះរួមមានទាំងមាត្រា ២០៣ នៃក្រមនីតិវិធី ព្រហ្មទណ្ឌកម្ពុជាដែលចែងថាជាទូទៅ "បុគ្គលត្រូវចោទ ត្រូវមានសេរីភាព" ក៏ដោយ ហើយមាត្រា ២០៤ ដែលរឹតត្បឹត ការឃុំខ្លួនបណ្តោះអាសន្នតែសម្រាប់ការចោទប្រកាន់ទៅលើបទល្មើសដែលមានកម្រិតទោសជាប់ពន្ធនាគារអប្បបរមា មួយឆ្នាំប៉ុណ្ណោះ ។ ខណៈដែលច្បាប់ ស្នើឡើងថា ការឃុំខ្លួនបណ្តោះអាសន្ន គួរប្រើប្រាស់ឲ្យបានតិចតួចបំផុត នៅពេលដែលកាលៈទេសៈមានការធានាហើយនោះក៏ដោយ[18] ក៏នៅក្នុងការអនុវត្តជាក់ស្តែង មនុស្សភាគច្រើនត្រូវបានគេឃុំខ្លួនមុនសវនាការ។ ក្នុងឆ្នាំ២០១៧ មនុស្សទាំងនេះ រួមមានទាំងអ្នកដែលត្រូវបានចោទពី បទប្រើប្រាស់ថ្នាំញៀន ប៉ុន្តែមិនមែនជាអ្នកលក់ថ្នាំញៀន និងមនុស្សដែលត្រូវបានគេចោទថា ប្រើប្រាស់ Facebook ដើម្បី ប្រមាថដល់រដ្ឋាភិបាល។

ការបារម្ភមួយទៀត គឺការកើនឡើងនៃចំនួនស្រ្តីមានផ្ទៃពោះដែលជាប់ក្នុងពន្ធនាគារ និងកុមារដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ[19]។

13 Catherine Burns និង Kathleen Daly, "ការឆ្លើយតបទៅនឹងការរំលោភសេពសន្ទវៈដែលកើតឡើងរាល់ថ្ងៃក្នុងប្រទេសកម្ពុជា៖ រោហាសាស្រ្ត, តថភាព និងការសម្រុះសម្រួល" សំណៅកែសម្រួលឡើងវិញ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣។ ttps://www.griffith.edu.au/__data/assets/pdf_-file/0016/650230/Burns-and-Daly-Pre-print-18-Dec-2013-Everyday-rape,-Cambodia,-somroh-somruel.pdf

14 របាយការណ៍អង្គការលីកាដូ "ការរួចខ្លួនពីបទល្មើស៖ ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈក្នុងប្រព័ន្ធតុលាការកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០១៥) មានព័ត៌មានលម្អិតអំពីប្រធានបទនេះ។ របាយការណ៍របស់អង្គការលីកាដូ "បើគ្មានការផ្តន្ទាទោស គឺគ្មានការការពារ៖ ការឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា" (ខែធ្នូ ឆ្នាំ២០១៧) មានព័ត៌មានលម្អិតបន្ថែមអំពីរបៀបដែលប្រព័ន្ធយុត្តិធម៌ឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារ។

15 មុិច តារា, "ចំនួនពន្ធនាគារកើន ២០%" ថ្ងៃទី២៣ ខែកុម្ភៈ ២០១៧, ភ្នំពេញប៉ុស្តិ៍ http://www.phnompenhpost.com/national/prison-numbers-jump-20-percent

16 មុិច តារា, "ព្រៃសមានភាពណែនចង្អៀត ទោះបីមានពន្ធនាគារថ្មីចំនួនពីរ" ថ្ងៃទី៣១ ខែតុលា ២០១៧, ភ្នំពេញប៉ុស្តិ៍ http://www.phnompenhpost.com/national/prey-sar-still-overcrowded-despite-two-new-prisons

17 http://www.prisonstudies.org/country/cambodia; ការស្រាវជ្រាវរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

18 ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា២០៥ អំពីបញ្ជីមូលហេតុ។

19 ទោះបីជារដ្ឋាភិបាលបានដោះលែងស្រ្តីជាច្រើនដែលមានកូនតូចកាលពីពីរឆ្នាំមុនក៏ដោយ ក៏ចំនួននេះ បានកើនឡើងម្តងទៀត លើសពីចំនួនកាលពីលើកមុន។ អគ្គនាយកពន្ធនាគារ បានបង្ហាញពីតួរលេខថា មានស្រ្តីមានផ្ទៃពោះចំនួន ៦១% កំពុងស្ថិតនៅក្នុងពន្ធនាគារចំនួន ២៩ នៅក្នុងខែ មេសា ឆ្នាំ ២០១៧ ។ គ្រាន់តែនៅក្នុងពន្ធនាគារដែលអង្គការសមាជិក NGO-CEDAW គឺអង្គការលីកាដូបានឃ្លាំមើលនោះ មានកុមារចំនួន១០៨នាក់ និងស្រ្តីមានផ្ទៃពោះចំនួន៤១នាក់ គិតត្រឹមខែតុលា ឆ្នាំ២០១៧។ នេះជាការកើនឡើងកុមារចំនួន ១៨១នាក់ និង ស្រ្តីមានផ្ទៃពោះ ៧៧ នាក់ នៅត្រឹមខែ ធ្នូ ឆ្នាំ ២០១៧ ។ ចំនួននេះ មិនទាន់រាប់បញ្ចូលអនីតិជន ដែលត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសដោយសារប្រព្រឹត្តិបទល្មើសនៅឡើយទេ។

ច្បាប់ស្តីពីពន្ធនាគាររបស់ប្រទេសកម្ពុជា[20] អនុញ្ញាតឲ្យម្តាយដែលមានកូនអាយុក្រោម៣ឆ្នាំរស់នៅ ជាមួយកូននៅក្នុងពន្ធនាគារ។ មាត្រា៤១នៃច្បាប់ស្តីពីពន្ធនាគារ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ និងវិធានទីក្រុងបាងកក តម្រូវឲ្យរដ្ឋបង់ការចំណាយសម្រាប់ការថែទាំកូនទាំងនេះ ប៉ុន្តែតាមជាក់ស្តែង រដ្ឋាភិបាលបានផ្តល់អោយតែជាង ១ពាន់ រៀលប៉ុណ្ណោះ ក្នុងមួយថ្ងៃសម្រាប់ក្មេងម្នាក់ ហើយម្តាយត្រូវបង្ខំចិត្តបង់ថ្លៃចំណាយនេះ ដោយខ្លួនឯងសម្រាប់តម្រូវការចាំបាច់ជាមូលដ្ឋាន។អ្នកជាប់ក្នុងពន្ធនាគារ និងកូន ត្រូវទទួលទានដំណេកនៅលើឥដ្ឋ និងមិនមានម្ហូបអាហារ ទឹកស្អាតគ្រប់គ្រាន់ ឬការថែទាំសុខភាព វេជ្ជសាស្ត្រឲ្យបានជាប់លាប់នោះទេ។ ម្តាយទើបឆ្លងទន្លេមិនបានទទួលការថែទាំក្រោយពេលសម្រាលទេ ។ ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូនមិនបានទទួលអាហារបំប៉នទេ។ តម្រូវការផ្នែកអនាម័យចាំបាច់បឋមដូចជា សាប៊ូដុសខ្លួន សំឡីអនាម័យ និងកន្លែងរស់នៅស្អាត មានសភាពខ្វះខាតនៅឡើយ។ ជារឿយៗ កុមារមិនបានធ្វើលំហាត់ប្រាណទេ ហើយត្រូវនៅក្នុងបន្ទប់ឃុំឃាំងដែលមានភាពចង្អៀតណែន ដែលគ្មានពន្លឺថ្ងៃឬសកម្មភាពអ្វីទៅវិញ[21] ។

**អនុសាសន៍៖**

ផ្លាស់ប្តូរច្បាប់និងគោលនយោបាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ជាពិសេសទាក់ទងនឹងស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូនតូច។ រដ្ឋគួរអនុវត្ត កម្មវិធីដោះលែងមុនសវនាការដែលមានការត្រួតពិនិត្យ និងការដាក់ទោសជំនួសដោយមិនជាប់ឃុំឃាំង ដោយរាប់បញ្ចូលទាំងទោសក្នុងការអនុវត្តសេវាសហគមន៍។ ការធ្វើបែបនេះ នឹងកែលម្អស្ថានភាពរបស់ពន្ធនាគារ សម្រាប់ជនដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ និងអាចប្រព្រឹត្តិទៅលើស្ត្រីដោយសេចក្តីថ្លៃថ្នូរ។ ត្រូវមានកិច្ចប្រឹងប្រែងជាពិសេស ដើម្បីទុកស្ត្រីមានផ្ទៃពោះនិងម្តាយដែលមានកូនតូច នៅក្រៅពន្ធនាគារ ដើម្បីកុំឲ្យកូនរបស់ស្ត្រីទាំងនេះ ទទួលរងការប៉ះពាល់ដោយសារការចិញ្ចឹមនៅក្នុងពន្ធនាគារ។

ប្រទេសកម្ពុជា ត្រូវការកម្មវិធីសាកល្បងមួយសម្រាប់មណ្ឌលច្រកចេញចូលតែមួយនៅក្រុងភ្នំពេញសម្រាប់កុមារីនិងស្ត្រីដែលប្រឈមនឹងអំពើហិង្សាលើយេនឌ័រ។

20 ច្បាប់ស្តីពីពន្ធនាគារ អាចទាញយកបានជាភាសាអង់គ្លេសនិងភាសាខ្មែរ នៅ http://cambodia.ohchr.org/en/prison-reform/laws-pertaining-prisons

21 ទិន្នន័យឃ្លាំមើលពីអង្គការនានាដែលធ្វើការជាមួយស្ត្រីនិងកុមារក្នុងពន្ធនាគារ

# មាត្រា 3

## សមភាពលើគ្រប់វិស័យរបស់ស្ត្រី គួរត្រូវបានសម្រេច តាមរយៈវិធានការសមស្របនានា

រដ្ឋាភិបាលកម្ពុជាបានអនុម័តផែនការសកម្មភាព និងគោលនយោបាយជាច្រើនដែលជាជំហ៊ានដ៏ខ្លាំងពូកែក្នុងការឈានឆ្ពោះទៅរកការទទួលស្គាល់ភាពស្មើគ្នារវាងស្ត្រី និងបុរសនៅគ្រប់វិស័យ ។ ក៏ប៉ុន្តែបញ្ហាចម្បងស្ថិតនៅត្រង់ ការអនុវត្តផែនការទាំងនេះឲ្យបានពេញលេញ។ មូលហេតុចម្បងមួយសម្រាប់បញ្ហានេះគឺថារដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ថវិកាច្រើនល្មមសម្រាប់ចំណាយទៅលើការបណ្តុះបណ្តាលបច្ចេកវិទ្យានិងបុគ្គលិកដែលត្រូវការសម្រាប់អនុវត្តឲ្យបានពេញលេញនូវផែនការនារីរតនៈ (ដែលជាផែនការសមភាពយេនឌ័រទាំងមូល) និងផែនការសកម្មភាពជាតិសម្រាប់ទប់ស្កាត់អំពើហិង្សាលើស្ត្រី។ មូលហេតុសំខាន់ទីពីរ គឺថារដ្ឋាភិបាលកម្ពុជាបានដាក់ការទទួលខុសត្រូវភាគច្រើនបំផុតក្នុងការគ្រប់គ្រងចាត់ចែងផែនការទាំងនេះទៅលើក្រសួងកិច្ចការនារីដែលជាក្រសួងតូចមួយមិនសូវមានឥទ្ធិពលនិងធនធានដូចក្រសួងដទៃទៀតទេ។ ថវិការបស់ក្រសួងមានចំនួនតិច បើប្រៀបធៀបនឹងការទទួលខុសត្រូវរបស់ក្រសួងនេះដូច្នេះហើយគួរមានការពិនិត្យឡើងវិញនិងបង្កើនការផ្តល់ថវិកាជារៀងរាល់ឆ្នាំ។ មូលហេតុចុងក្រោយគឺថា ភាគច្រើននៃកម្មវិធីពិតប្រាកដដែលពាក់ព័ន្ធទៅនឹងផែនការទាំងនេះ និងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនោះតាមពិតទៅត្រូវបានផ្តល់មូលនិធិ និងអនុវត្តដោយអង្គការ មិនមែនរដ្ឋាភិបាល និងដោយរដ្ឋាភិបាលមជ្ឈឹមប្រទេសមួយចំនួន[22]។

ការពឹងផ្អែកជ្រុលពេកទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់សេវាកម្មនិងអនុវត្តកម្មវិធីដើម្បីសម្រេចគោលដៅជាតិនៃសមភាពយេនឌ័រនាំឲ្យមានការអនុវត្តមិនស៊ីសង្វាក់គ្នា និងមិនពេញលេញទៅលើផែនការសកម្មភាពនានាដែលមានលក្ខណៈបណ្តោះអាសន្នដោយសារអង្គការមិនមែនរដ្ឋាភិបាលទាំងនោះបានទទួលមូលនិធិសម្រាប់គម្រោងរយៈពេលខ្លី និងកម្មវិធីសាកល្បងតែប៉ុណ្ណោះ។

គម្រោងទាំងនេះទោះបីជាជោគជ័យខ្លាំងក៏ដោយ ក៏មិនមានការអនុវត្តបន្តក្នុងឆ្នាំខាងមុខទៀត ដោយ អង្គការមិនមែនរដ្ឋាភិបាល ឬអនុវត្តបន្តដោយរដ្ឋាភិបាលទេ ដោយសារតែកង្វះការផ្តល់មូលនិធិ។ ឧទាហរណ៍ មានខ្សែទូរស័ព្ទបន្ទាន់សម្រាប់បញ្ហាអំពើហិង្សាលើយេនឌ័រ ប៉ុន្តែគ្មាននរណាម្នាក់នៅទទួលទូរស័ព្ទទេចាប់តាំងពីរយៈពេលទទួលមូលនិធិរបស់កម្មវិធី នោះបានបញ្ចប់ទៅ។

ជាងនេះទៀតដូចបានកត់សម្គាល់នៅក្នុងរបាយការណ៍របស់រដ្ឋភាគី គឺថាមិនមានផ្ទះសុវត្ថិភាព ឬជម្រក សម្រាប់អ្នករងអំពើហិង្សាក្នុងគ្រួសារ ដែលប្រតិបត្តិការដោយរដ្ឋាភិបាលទេគឺមានតែមណ្ឌលមួយចំនួនតូចដែលដំណើរការ ដោយអង្គការមិនមែនរដ្ឋាភិបាលនានា នៅក្នុងឬនៅក្បែរទីក្រុងតែប៉ុណ្ណោះ។ កម្មវិធីមួយដែលអាចកាត់បន្ថយការខ្វះខាតសេវាសម្រាប់ជនរងគ្រោះនៃការជួញដូរ និងអំពើហិង្សាលើយេនឌ័រនោះគឺមណ្ឌលច្រកចេញចូលតែមួយ ។ ការសិក្សាពីសមិទ្ធិលទ្ធភាពកាលពីឆ្នាំ២០១១បានស្នើឡើងថា ប្រទេសកម្ពុជាមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់មណ្ឌលបែបនេះនៅឡើយទេ ប៉ុន្តែគួរចាប់ផ្តើមកម្មវិធីសាកល្បងមួយក្នុងរយៈពេលពីរបីឆ្នាំខាងមុខ បន្ទាប់ពីកសាងសមត្ថភាពនិងអនុម័តរចនាសម្ព័ន្ធជាតិដើម្បីដោះស្រាយអំពើហិង្សាលើយេនឌ័រនេះ។ ពេលនេះប្រទេសកម្ពុជាត្រៀមខ្លួនរួចរាល់ហើយ។

**អនុសាសន៍៖**

រដ្ឋាភិបាល ត្រូវផ្តល់ធនធានថវិកាដើម្បីបន្តកម្មវិធីសាកល្បង ដែលទទួលបានជោគជ័យនៅពេលចាប់ផ្តើមដោយជំនួយបរទេស។ រដ្ឋគឺជាតួអង្គតែមួយគត់ ដែលមានសមត្ថភាពក្នុងការធ្វើសមាហរណកម្មកម្មវិធីណាមួយប្រកបដោយចីរភាពនិងពេញលេញនៅទូទាំងប្រទេស នៅថ្នាក់មូលដ្ឋាន នៅក្នុងវិស័យការងារ អប់រំ សុខាភិបាល ការការពារបរិស្ថាន និងការប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រ ដែលរីករាលដាលនៅក្នុងសង្គមកម្ពុជា។

22 កម្មវិធី NAPPVAW ត្រូវបានអនុវត្តដោយសហការជាមួយប្រទេសអាឡឺម៉ង់ និងអូស្ត្រាលី ក្នុងខណៈដែលសេវាកម្មផ្លូវច្បាប់ សុខភាពបន្តពូជ និងសង្គមភាគច្រើនបំផុតត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ លទ្ធផលទាំងនេះ គាំទ្រដោយការសម្ភាសន៍ជាមួយសមាជិកអង្គការ NGO-CEDAW និងអង្គការមិនមែន រដ្ឋាភិបាលអន្តរជាតិនានាដែលផ្តល់សេវាកម្មដោយផ្ទាល់ដល់ជនរងគ្រោះដោយអំពើហិង្សាផ្អែកលើភេទ និងធ្វើការជាមួយអាជ្ញាធរដែនដី ។

## មាត្រា 4

## ការចាត់វិធានការពិសេសបណ្តោះអាសន្នក្នុងការលើកកម្ពស់ស្ត្រី ត្រូវបានលើកទឹកចិត្ត នៅក្រោមអនុសញ្ញាស៊ីដ ហើយមិនត្រូវបានចាត់ទុកជាការរើសអើងនោះទេ

គួរអោយសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រកាសម្តងហើយម្តងទៀតនៅក្នុងសន្និសីទសារព័ត៌មានអំពីការចាប់យកគោលដៅស្ម័គ្រចិត្តផែនការសកម្មភាព និងគោលនយោបាយនានាក្នុងការបង្កើនចំនួនស្ត្រី នៅក្នុងតំណែងនយោបាយដែលមានការបោះឆ្នោតនិងតាមរយៈការតែងតាំង និងនៅក្នុងមុខងារសាធារណៈ។ វិធានការបែបនេះពិតជាមានសារៈ សំខាន់ក្នុងការអនុវត្តអនុសញ្ញា ស៊ីដ អោយបានពេញលេញ និង បង្ហាញពីបំណងល្អរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីឈានឆ្ពោះទៅរកការសម្រេចបាននូវកាតព្វកិច្ចជារដ្ឋហត្ថលេខី ។ ក៏ប៉ុន្តែ យើងឃើញថាមិនទាន់មានការបង្កើតអាណត្តិតាមផ្លូវច្បាប់និងការគាំទ្រជាថវិកាណាមួយដល់ការតំណាងរបស់ស្ត្រីនៅក្នុងផ្នែកអភិបាលកិច្ចនយោបាយ នៅថ្នាក់ជាតិឬថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជាឡើយ។ដូច្នេះគោលដៅតាមការស្ម័គ្រចិត្តទាំងនោះច្រើនតែមិនបានអនុវត្តហើយក៏មិនមានផលលំបាកអ្វីកើតឡើងដែរពីការខកខានមិនបានសម្រេចតាមគោលដៅទាំងនេះឡើយ។

ថ្នាក់ដឹកនាំនយោបាយច្រើនតែអះអាងថា ស្ត្រីមិនទាន់មានតំណាងគ្រប់គ្រាន់នៅក្នុងវិស័យនយោបាយនៅឡើយពីព្រោះស្ត្រីមិនទាន់មានគុណវុឌ្ឍគ្រប់គ្រាន់[23]។ ក៏ប៉ុន្តែ ទឡ្ហីករណ៍នេះត្រូវបានគណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ បដិសេធចោលនៅក្នុងអនុសាសន៍ទូទៅលេខ ២៥[24] ។

ផ្នត់គំនិតខុសឆ្គងនិងនិយាមអវិជ្ជមានអំពីយេនឌ័របានរួមចំណែកដល់ការបង្កើតលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសដែលមានការរើសអើងដោយថ្នាក់ដឹកនាំគណបក្សនយោបាយធំៗទាំងអស់។ រចនាសម្ព័ន្ធអំណាចដែលត្រួតត្រាដោយបុរសនៅក្នុងគណបក្សនយោបាយនានា ធ្វើឲ្យមានការលំបាកសម្រាប់បេក្ខជនជាស្ត្រីឲ្យមានភាពជឿជាក់ទៅលើការតែងតាំងខ្លួននៅផ្នែកខាងលើនៃបញ្ជីឈ្មោះណាស់ ។ លក្ខណៈវិនិច្ឆ័យដែលគណបក្សនយោបាយ និងមន្ត្រីរដ្ឋាភិបាលបានប្រើក្នុងការតែងតាំងមាន ឥទ្ធិពលជាក់ស្តែងក្នុងការដកស្ត្រីភាគច្រើនចេញពីដំណើរការនយោបាយ ទោះបីជាមានចេតនាពីថ្នាក់ដឹកនាំក្នុងការមិនរើសអើងទៅលើស្ត្រីក៏ដោយ។ ដើម្បីប្រឆាំងនឹងភាពលម្អៀងលាក់មុខនេះ គេត្រូវចាត់វិធានការពិសេសបណ្តោះអាសន្នដើម្បីដាក់ស្ត្រីនៅក្នុងតួនាទីជាថ្នាក់ដឹកនាំ។ កាលណាស្ត្រី ត្រូវបានដាក់នៅក្នុងតួនាទីដែលមានអំណាចកាន់តែរហ័ស វត្តមានរបស់ពួកគេនឹងមានលទ្ធភាពក្នុងការផ្លាស់ប្តូរនិយាមយេនឌ័រ និងលើកទឹកចិត្តដល់មេដឹកនាំស្ត្រីជំនាន់ថ្មីកាន់តែឆាប់រហ័សដែរ។

23 ប្រទេសកម្ពុជាមិនមានការសរសេរជាលាយលក្ខអក្សរនូវគុណវុឌ្ឍ សម្រាប់មុខតំណែងជាច្រើន ហើយមានបុរសដែលមិនមានសមត្ថភាពជាច្រើនត្រូវបានជ្រើសរើសសម្រាប់មុខតំណែងទាំងនោះ ។

24 អនុសាសន៍ទូទៅលេខ ២៥, កថាខណ្ឌ២៣ គណៈកម្មការអនុសញ្ញាស៊ី ដ របស់អង្គការសហប្រជាជាតិចែងថា ដោយសារតែវិធានការពិសេសបណ្តោះអាសន្នមានគោលបំណងពន្លឿនការសម្រេចបាននូវសមភាពតាមផ្លូវច្បាប់និងសមភាពសំខាន់ៗនោះ សំណួរទាក់ទងនឹងគុណវុឌ្ឍនិងស្នាដៃ ... ត្រូវពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នទាក់ទងនឹងការលម្អៀងយេនឌ័រ ដោយសារតែវាកំណត់ដោយនិយាមធម្មតានិងវប្បធម៌។ សម្រាប់ការតែងតាំង ការជ្រើសរើស ឬការបោះ ឆ្នោតជ្រើសតាំងចូលកាន់តំណែងសាធារណៈឬតំណែងនយោបាយ ក្រៅពីគុណវុឌ្ឍនិងស្នាដៃ កត្តាផ្សេងទៀតដូចជា ការប្រើប្រាស់គោលការណ៍ភាពយុត្តិធម៌បែបប្រជាធិបតេយ្យ និងជម្រើសតាមការបោះឆ្នោត អាចដើរតួនាទីមួយដែរ។

## មាត្រា 5

## រដ្ឋភាគីត្រូវតែលុបបំបាត់នូវការអនុវត្តបែបវប្បធម៌ និងប្រពៃណីទាំងឡាយណា ដែលមានលក្ខណៈរើសអើង ហើយលើកតម្កល់តួនាទីស្មើគ្នាក្នុងការចិញ្ចឹមបីបាច់កូន

ផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រទៅលើស្ត្រី នៅតែកើតមានបន្តនៅក្នុងសង្គម និងដើរតួនាទីក្នុងការរារាំងមិនឲ្យស្ត្រីទទួលបានតួនាទីក្នុងការសម្រេចចិត្តឲ្យបានច្រើន ការទទួលបានការថែទាំសុខភាពបន្តពូជ និងគេចផុតពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាលើរាងកាយ។

ការរំលោភសេពសន្ថវៈនៅតែមានអាត្រាខ្ពស់ជាពិសេសនៅក្នុងប្រទេសកម្ពុជាមួយផ្នែកដោយសារតែឥរិយាបថដែល គិតថាជនរងគ្រោះ គឺជាអ្នកទទួលខុសត្រូវសម្រាប់អំពើហិង្សាផ្លូវភេទ[25] និងមួយផ្នែកដោយសារតែ កង្វះវិធានការសង្គម និងផ្លូវ ច្បាប់សម្រាប់ជនល្មើស[26] ។

អំពើហិង្សាពីដៃគូស្និទ្ធស្នាល នៅតែមានភាពរីករាលដាលពាសពេញប្រទេសកម្ពុជា។ ទោះបីជាកិច្ចប្រឹងប្រែងមានការកើនឡើងពីរដ្ឋាភិបាលជាតិ ក្នុងការលើកកម្ពស់ការយល់ដឹងថាអំពើហិង្សាក្នុងគ្រួសារជាទង្វើខុសក៏ដោយ ក៏គោលនយោបាយរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់មូលដ្ឋានបន្តប្រើប្រាស់ការសម្រុះសម្រួលជាដំណោះស្រាយដែលគេចង់បានសម្រាប់បញ្ហាអំពើហិង្សាក្នុងគ្រួសារដដែល។ ខណៈដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ មានវិធានការការពារពីរប្រភេទផ្សេងគ្នា (សេចក្តីសម្រេចរដ្ឋបាលដោយក្រុមប្រឹក្សាឃុំនៅមូលដ្ឋាន និងដីកាការពាររបស់តុលាការ) ក៏ដោយ ក៏វិធីសាស្ត្រក្នុងការ ទប់ស្កាត់អំពើហិង្សាដោយដៃគូស្និទ្ធស្នាលមិនដែលមានភាពដាច់ខាតដោយច្បាប់ទេ ហេតុដូច្នេះហើយគេសឹងតែមិនដែលបាន ប្រើវិធីសាស្ត្រទាំងនេះទេ[27] សូម្បីតែជាមួយនឹងវិធីសាស្ត្រសម្រុះសម្រួលក៏ដោយ។ មិនមានការការពារណាមួយចែងក្នុង ច្បាប់សម្រាប់ស្ត្រីដែលមិនរស់នៅជាមួយដៃគូរបស់ខ្លួនឡើយដោយរាប់ទាំងអ្នកដែលត្រូវបានដៃគូរឈ្លបតាមធ្វើបាបបន្ទាប់ពីពួកគេប៉ុនប៉ងរស់នៅកន្លែងផ្សេងទៀតក៏ដោយ។ រដ្ឋាភិបាលគឺត្រូវបានស្នើអោយបញ្ចូលនៅក្នុងផែនការសកម្មភាពថ្មី ស្តីពីការ ការពារ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារធ្វើវិសោធនកម្មខ្លះលើច្បាប់ទប់ស្កាត់អំពើហិង្សា នឹងកិច្ចការពារជនរងគ្រោះ ក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី និងបន្ថែមនូវបទបញ្ញានានា ដើម្បីបញ្ជាក់អំពីការប្រើសេចក្តីសម្រេចរដ្ឋបាលនេះ[28]។ ការធ្វើវិសោធនកម្មទាំងនេះគួរតែបញ្ចូលផងដែរនូវបញ្ញត្តិក្នុងការការពារស្ត្រី និងមនុស្សផ្សេងទៀតដែលប្រឈមនឹងគ្រោះថ្នាក់នៃអំពើហិង្សា ។

បុព្វហេតុដែលពិបាកជាងគេមួយ ដែលការបន្តកើតមានអំពើហិង្សាក្នុងគ្រួសារមិនដាច់នេះ គឺឥរិយាបថដែលថាអំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាគ្រួសារជាជាងឧក្រិដ្ឋកម្មដែលធ្វើឲ្យឈឺចាប់ដល់មនុស្សទាំងអស់នៅក្នុងសង្គមហើយនៅក្នុងកាលៈទេសៈខ្លះ អំពើហិង្សាត្រូវបានបង្ហាញថាអាចទទួលយកបាន[29]។ ផ្នត់គំនិតរបស់បុរសអំពីមនុស្សស្រីរួមចំណែកបង្កឲ្យមានអំពើហិង្សាដោយសារតែបុរសជាច្រើនជឿថាប្រពន្ធនិងកូនស្រីរបស់ខ្លួនជាកម្មសិទ្ធិរបស់ពួកគេ[30]។ ខ្សែភាពយន្តនិងកម្មវិធីកំសាន្តតាមទូរទស្សន៍ជាច្រើនហាក់ដូចជាពង្រឹងឥរិយាបថទាំងនេះតាមរយៈការបង្ហាញរូបភាពនៃអំពើហិង្សាក្នុងសភាពមួយដែលជាការស្នើឡើងថា អាកប្បកិរិយាបែបនេះជាការអាចទទួលយកបាន។ កិច្ចខិតខំប្រឹងប្រែងជាច្រើនរបស់រដ្ឋាភិបាល ទាក់ទងនឹង រូបភាពរបស់ស្ត្រីនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានដឹកនាំដោយគណៈកម្មាធិការជាតិសម្រាប់លើកកម្ពស់សីលធម៌សង្គមកម្ពុជាតម្លៃស្ត្រី និងគ្រួសារខ្មែរ និងបានស្តីបន្ទោសតារាសម្តែងស្ត្រីដែលបង្ហាញពីភាពមិនសមរម្យក្នុងការស្លៀកពាក់[31] ។ ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងអំពើហិង្សាលើស្ត្រីក៏បាន បញ្ចូលការប្រើប្រាស់សម្តីពាក្យពេចន៍ដែលមានការបន្ទាបតម្លៃរបស់ជនរងគ្រោះនិងកង្វះការគោរពភាពសម្ងាត់ទាក់ទងនឹងឈ្មោះជនរងគ្រោះនិងរូបភាពនៃអំពើហិង្សាដែរ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានអនុម័តប្រកាសរួមមួយស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយក្នុងការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី [32]។

25 អង្គការ ActionAid, "ការសិក្សាអំពីពិរុទ្ធភាព៖ តើស្រីមានកំហុសប៉ុណ្ណា សម្រាប់ការរំលោភបំពានផ្លូវភេទដែលពួកគេទទួលរង" ២០១៦

26 របាយការណ៍អង្គការលីកាដូ "ការរួចខ្លួនពីប្រព្រឹត្តបទល្មើស" ឆ្នាំ២០១៥។

27 កំណត់សម្គាល់សេចក្តីព្រាងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាកាលពីខែកញ្ញា ឆ្នាំ២០១៧, ពីឆ្នាំ២០១៤-១៦ តុលាការចំនួន១៩ បានចេញដីកាការពារ នៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៀត មានខេត្តចំនួនតែពាក់កណ្តាលប៉ុណ្ណោះក្នុងប្រទេសកម្ពុជាំដែលមានទម្រង់និងប្រព័ន្ធរួចរាល់។

28 ផែនការសកម្មភាពនេះគឺជាការគាំទ្ររួមរវាងក្រសួងកិច្ចការនារី និក្រសួងសង្គមកិច្ច អតីតយុវជន និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយត្រូវបានផ្ទផ្សាយដាក់អោយអនុវត្តជាផ្លូវការនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៧ ។

29 ការស្ទង់មតិថ្នាក់ជាតិស្តីពីសុខភាពនិងជីវិតរំពឹងរស់របស់ស្ត្រីក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៥ http://www.wpro.who.int/mediacentre/releas-es/2015/vaw_full-en.pdf

30 ការសម្ភាសន៍អង្គការជាតិ និងអន្តរជាតិ Hagar interview, ថ្ងៃទី២៣ មិថុនា ២០១៧ ដែលធ្វើការលើអំពើហិង្សាក្នុងគ្រួសារ ។

31 តារាសម្តែងស្រីម្នាក់ត្រូវបានហាមឃាត់ក្នុងឆ្នាំ២០១៧ មិនឲ្យបង្ហាញមុខក្នុងខ្សែភាពយន្តរយៈពេលមួយឆ្នាំ ដោយសារតែការស្លៀកពាក់បញ្ចេញសាច់ច្រើន ដែលជាការបំពានទៅលើក្រមសីលធម៌សម្រាប់សិល្បករ។ ផាន់ ស៊ូមី "រដ្ឋាភិបាលហាមឃាត់តារាសម្តែងស្រីមួយឆ្នាំដោយសារបំពាន "ក្រមសីលធម៌" កាសែត Cambodia Daily, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧

32 ប្រកាសរួមដែលចេញដោយក្រសួងព័ត៌មាននិងក្រសួងកិច្ចការនារី

ក្រមប្រតិបត្តិនេះ គឺជាជំហានល្អមួយក្នុងការធ្វើឲ្យមានការគិតជាធម្មតា អំពីឥរិយាបថដែលថាស្ត្រីរងគ្រោះដោយសារអំពើហិង្សាមិនគួរត្រូវបានគេកេងចំណេញនោះទេ។ ជាអកុសលបន្ទាប់ពីក្រមប្រតិបត្តិនេះចូលជាធរមានភ្លាម យ៉ាងតិចណាស់មានពិធីករទូរទស្សន៍ធំមួយ បានបំពានទៅលើក្រមប្រតិបត្តិនោះភ្លាម[33] ។ ជំនួសឲ្យការរឹតត្បឹតការបញ្ចេញមតិដោយសេរី ឬដាក់ទោសទណ្ឌទៅលើស្ត្រីដោយសារតែអាកប្បកិរិយារបស់ស្ត្រីនោះ គេត្រូវធ្វើការច្រើនថែមទៀតដើម្បីផ្លាស់ប្តូរឥរិយាបថទូទៅ ដើម្បីលើកទឹកចិត្តឲ្យមានការគោរពសិទ្ធិស្ត្រីនិងកុមារីក្នុងការទទួលបានការរស់នៅដោយគ្មានអំពើហិង្សា។

អាជ្ញាធរដែលត្រូវបានគេទាក់ទងទៅ នៅពេលដែលជនរងគ្រោះដោយសារអំពើហិង្សាស្វែងរកជំនួយ ជារឿយៗ ខ្វះខាតជំនាញសម្ភាសន៍ និងការយល់ដឹងអំពីបញ្ហានេះ ក្នុងការផ្តល់ការប្រឹក្សាយោបល់។ ជារឿយៗ មានការរាយការណ៍ថាអាជ្ញាធរច្រើនតែប្រើប្រាស់ពាក្យសម្តីប្រមាថ និងបន្ទោសជនរងគ្រោះ សម្រាប់អំពើហិង្សាដែលពួកគេទទួលរងទៅវិញ។ទោះបីជារដ្ឋាភិបាលបានបង្កើតសៀវភៅណែនាំប្រឹក្សាយោបល់មួយដែលបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១៧ក៏ដោយ ក៏សៀវភៅនោះ មានលក្ខណៈបច្ចេកទេសពិបាកយល់និងមានគោលបំណងប្រើប្រាស់ការណែនាំទាំងអស់នេះ ជាមួយអ្នកវិជ្ជាជីវៈវេជ្ជសាស្ត្រ អ្នកពង្រឹងការអនុវត្តច្បាប់ អង្គការមិនមែនរដ្ឋាភិបាលនិងមន្ត្រីរដ្ឋាភិបាល។ការបណ្តុះបណ្តាលជាក់លាក់ចំពោះក្រុមនីមួយៗ នៅថ្នាក់ភូមិគឺចាំបាច់ និងត្រូវការការវិនិយោគបន្ថែមពីរដ្ឋាភិបាល។

ក្រុមអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ)ទទួលរងនូវការប្រព្រឹត្តមិនគប្បីជាពិសេសដោយសារតែផ្នត់គំនិត យេនឌ័រអវិជ្ជមាន។ ឧទាហរណ៍ មានជំនឿពេញនិយមមួយថាក្រុមអ្នកស្រលាញ់ភេទដូចគ្នាជាជនដែលទទួលរងទណ្ឌកម្ម ដោយសារតែអំពើអាក្រក់អ្វីមួយដែលពួកគេបានសាងពីអតីតជាតិ។ជំនឿមួយទៀត អ្នកប្តូរភេទគឺជាជនឧក្រិដ្ឋ ឬក៏ អ្នកប្រើប្រាស់គ្រឿងញៀនដែលជាមូលហេតុនាំអោយមានអានាធិបតេយ្យក្នុងសង្គម។នៅក្នុងការបោះឆ្នោតលើកចុងក្រោយនេះ អ្នកសង្កេតការណ៍មួយចំនួនបានកត់សម្គាល់ថាមនុស្សដែលប្តូរភេទត្រូវបានគេធ្វើទុក្ខបុកម្នេញដោយសារតែមានរូបរាងមិនដូចភេទ ដែលមានដាក់នៅក្នុងអត្តសញ្ញាណប័ណ្ណរបស់ពួកគេត្រូវបានប្រាប់ឲ្យទៅដូររូបរាងសិនមុនមកបោះឆ្នោត ឬត្រូវបានគេសួររកឯកសារបន្ថែមសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ[34]។

ព័ត៌មានអំពីសិទ្ធិសុខភាពបន្តពូជ មិនអាចរកបានដោយស៊ីសង្វាក់នោះទេ។ ការស្រាវជ្រាវថ្មីៗនេះ បង្ហាញថាស្ត្រីជាច្រើនមិនបានដឹងអំពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងការពន្យារកំណើត ព្រមទាំងការធ្វើតេស្ត/ការព្យាបាលជំងឺកាមរោគ។ ឧទាហរណ៍ ពួកគេបានរៀបរាប់ថា ពួកគេមិនជឿថាស្ត្រីដែលរៀបការហើយ គួរប្រើប្រាស់វិធីពន្យារកំណើតទេ ដោយសារតែតួនាទីរបស់ពួកគេក្នុងគ្រួសារ គឺត្រូវមានកូន។ ពួកគេក៏បានរៀបរាប់ដែរ អំពីភាពអាម៉ាស ខ្លាចគេគិតអាក្រក់ដែលជាហេតុនាំឲ្យខ្លាចមិនហ៊ានសួរនាំឲ្យប្តីទៅស្វែងរកការព្យាបាលជំងឺកាមរោគ[35] ។

**អនុសាសន៍៖**

ផែនការប្រទេសកម្ពុជាក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបញ្ចប់អំពើហិង្សាលើស្ត្រី នៅចុងឆ្នាំ២០១៨។ ផែនការដែលបានធ្វើបច្ចុប្បន្នភាព ត្រូវបញ្ចូលការប្តេជ្ញាចិត្តផ្តល់ធនធាននិងមូលនិធិឲ្យបានច្រើន ដើម្បីលើកកម្ពស់រូបភាពវិជ្ជមានរបស់ស្ត្រី និងប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតខុសឆ្គងអំពីតួនាទីយេនឌ័រ។ ជាពិសេស រូបភាពវិជ្ជមានទាំងនោះ ត្រូវលើកកម្ពស់នៅថ្នាក់ភូមិ តាមរយៈការពន្យល់អំពីសិទ្ធិស្ត្រីនិងកុមារីក្នុងការរស់នៅដោយគ្មានអំពើហិង្សាគ្រប់ទម្រង់ សិទ្ធិក្នុងការទទួលបានការអប់រំ និងសិទ្ធិដើរតួនាទីជាថ្នាក់ដឹកនាំក្នុងសហគមន៍និងក្នុងរដ្ឋាភិបាល ព្រមទាំងសិទ្ធិក្នុងការធ្វើការសម្រេចចិត្តដោយខ្លួនឯងអំពីអាពាហ៍ពិពាហ៍ ការងារ និងការមានកូន។ ផែនការដែលបានធ្វើបច្ចុប្បន្នភាពទាំងនោះ គួរមើលឲ្យហួសពីរយៈពេលប្រាំឆ្នាំ ដើម្បីធានាឲ្យសម្រេចបានគោលដៅទី៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

33 ក្រសួងកិច្ចការនារី ថ្កោលទោសការរំលោភបំពាន៖ www.cambodiadaily.com/opinion/letter-editor-womens-ministry-condemns-rape-comment-133904/, ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧។

34 ការសម្ភាសន៍ជាមួយអង្គការ CamASEAN សមាគម និងអង្គការដែលធ្វើការជាមួយសហគមន៍ អ្នកស្រលាញ់ភេទដូចគ្នា

35 ការស្រាវស្រាវដោយប្រើឧបករណ៍តាមដាន ពីអង្គការ RHAC អង្គការដែលផ្តល់សេវាកម្មសុខភាពបន្តរពូជ ។

# មាត្រា 6

# រដ្ឋភាគីត្រូវតែចាត់នូវរាល់វិធានការសមស្របទាំងអស់ដើម្បីបង្ក្រាបការជួញដូរស្ត្រី និងអាជីវកម្មពេស្យាចារលើស្ត្រី

## ការជួញដូរស្ត្រីនិងកុមារី

ទោះជារដ្ឋាភិបាលមានការអភិវឌ្ឍន៍វិជ្ជមានសំខាន់ៗក្នុងការចាត់វិធានការប្រឆាំងនឹងអ្នកជួញដូរក៏ដោយក៏វានៅតែបន្តមានបញ្ហានានាទាក់ទងនឹងការជួញដូរនៅក្នុងប្រទេសកម្ពុជាទាំងក្នុងផ្ទៃប្រទេសនិងទាំងការបញ្ជូនមនុស្សឆ្លងដែន។

ការពង្រឹងការអនុវត្តច្បាប់ហាក់ដូចនៅមានការយឺតយ៉ាវក្នុងការដោះស្រាយបញ្ហាពីព្រោះចំណេះដឹងមន្ត្រីរដ្ឋាភិបាលមួយចំនួននៅតែមានកម្រិតអំពីការសម្ភាសន៍ និងការគោរពសិទ្ធិជនរងគ្រោះ។ ចំនួនស្ត្រីក្នុងតួនាទីពង្រឹងការអនុវត្តច្បាប់មាន អាត្រាទាប ក៏ជាការបន្ថែមបញ្ហាក្នុងការដោះស្រាយដោយផ្ទាល់ជាមួយជនរងគ្រោះដោយសារតែជនរងគ្រោះជាច្រើនមិនទុក ចិត្តអាជ្ញាធរដែលភាគច្រើនជាបុរស។

កិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល មិនទាន់បានរឹងមាំដូចដែលគួរតែមាននៅឡើយទេ។ មន្ត្រីរដ្ឋាភិបាលទាំងនៅក្នុងប្រទេសទទួល និងនៅក្នុងប្រទេសកម្ពុជា មិនទាន់បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលតាមកម្រិតដែលត្រូវការនៅឡើយទេ។

នៅមានការខ្វះខាតធ្ងន់ធ្ងរក្នុងវិស័យសេវាសង្គម ការគាំទ្រហិរញ្ញវត្ថុ និងធនធានមនុស្ស ដែលជនរងគ្រោះអាចរកបាននៅឡើយ។ បន្ថែមពីលើការបញ្ជូនស្ត្រី និងកុមារីទៅទីតាំងមានសុវត្ថិភាព និងកាត់ទោសអ្នកជួញដូរគេត្រូវការការយកចិត្តទុកដាក់ និងធនធានបន្ថែមទៀតដើម្បីធានាថាជនអ្នករួចជីវិតពីការជួញដូរទទួលបានការប្រឹក្សាយោបល់ការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ ការអប់រំអំពីសុខភាពបន្តពូជជំនួយផ្នែកច្បាប់ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនឹងអនុញ្ញាតឲ្យពួកគេបន្តដំណើរជីវិតទៅមុខ និងជៀសវាងកាលៈទេសៈដែលនឹងធ្វើឲ្យពួកគេងាយទទួលរងការជួញដូរជាថ្មីម្តងទៀត។

## ការកេងប្រវ័ញ្ចផ្នែកពេស្យាចារ

ច្បាប់ព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងការជួញដូររបស់ប្រទេសកម្ពុជា ផ្តោតទៅលើការកាត់ទោសនិងការរឹតត្បឹតជនដែលកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារីសម្រាប់បទល្មើសពេស្យាចារ ប៉ុន្តែច្បាប់ទាំងនេះក៏ដាក់ទណ្ឌកម្មទៅលើស្ត្រីដែលគួរតែទទួលបានការការពារដែរ។ ស្ត្រីដែលមានពាក់ព័ន្ធមិនមែនត្រឹមតែពាក់ព័ន្ធក្នុងការងារផ្លូវភេទប៉ុណ្ណោះទេ គឺថែមទាំងក្នុង ឧស្សាហកម្មកំសាន្តណាក៏ដោយ ក៏អាចត្រូវយកមកកាត់ទោសឬឃាយីរំខានដោយអាជ្ញាធរដែរ។ ស្ត្រីដែលត្រូវបានសង្ស័យថា មានការពាក់ព័ន្ធនឹងអំពើពេស្យាចារ ច្រើនតែត្រូវបានគេបដិសេធមិនផ្តល់ឲ្យនូវសេវាសំខាន់ៗពីអាជ្ញាធរមូលដ្ឋានត្រូវបានគេចាត់ទុកដូចជនប្រព្រឹត្តបទឧក្រិដ្ឋសូម្បីតែពួកគេមិនបានរំលោភច្បាប់ជាក់លាក់ណាមួយក៏ដោយ និងត្រូវបានដាក់ឲ្យឋិត នៅក្នុងភាពគ្រោះថ្នាក់។ នៅដើមឆ្នាំ២០១៧ ស្ត្រីម្នាក់បានលង់ទឹកស្លាប់បន្ទាប់ពីសន្តិសុខខណ្ឌមួយក្រុមបានដេញតាមនាងចុះ ទៅក្នុងទន្លេ ដោយសារតែពួកគេសង្ស័យថានាងជាអ្នករកស៊ីផ្លូវភេទ[36]។ ជាងនេះទៀត ដោយសារតែការខ្វះខាតការថែទាំសុខភាពបន្តពូជប្រកបដោយសុវត្ថិភាព អ្នករកស៊ីផ្លូវភេទ ទទួលរងគ្រោះថ្នាក់ក្នុងអាត្រាមរណៈមាតាខ្ពស់ខុសពីធម្មតាជារឿយៗ គឺទាក់ទងនឹងការរំលូតកូន[37]។

ដើម្បីធានាឲ្យមានការទទួលបានសេវាយុត្តិធម៌សម្រាប់ស្ត្រីដែលធ្វើការនៅក្នុងឧស្សាហកម្មកំសាន្តឲ្យជៀសផុតពីការ រំលោភបំពាន ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ គួរធ្វើវិសោធនកម្មដើម្បីលុបចោលការដាក់ទណ្ឌកម្មទៅលើបុគ្គលដែលគេសង្ស័យថាជាអ្នកប្រកបរបរពេស្យាចារ។ កិច្ចប្រឹងប្រែងប្រឆាំងការជួញដូរគួរផ្តោត ទៅលើបុគ្គលដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារ និងមិនគួរផ្តោតទៅលើបុគ្គលដែលត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងឧស្សាហកម្មផ្លូវភេទនោះទេ។

**អនុសាសន៍៖**

ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ក្រមព្រហ្មទណ្ឌ និងច្បាប់ជួញដូរឲ្យអនុលោមតាមអនុសញ្ញាស៊ី ដ។ ត្រូវដកចេញទោសប្បញ្ញត្តិសម្រាប់ការងារផ្លូវភេទ។ ត្រូវបញ្ជាក់ឲ្យច្បាស់ថាការរំលោភសេពសន្ធវៈគឺសំដៅដល់ការរួមភេទទាំងឡាយណាដែលមិនមានការយល់ព្រម ទោះបីជាបុគ្គលនោះរៀបការរួចហើយក៏ដោយ ឬស្ថិតនៅក្នុងចំណងអាហ៍ពិពាហ៍។

36 សុខ ឧត្តម្ភ "អ្នកផ្តល់សេវាផ្លូវភេទបាត់ខ្លួនក្នុងទន្លេបន្ទាប់ពីគេចពីកងសន្តិសុខ", កាសែត The Cambodia Daily, ថ្ងៃទី៣ មករា ២០១៧

37 "ហានិភ័យលាក់កំបាំងសម្រាប់អ្នកផ្តល់សេវាផ្លូវភេទ", Erin Handley, ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៨ វិច្ឆិកា ២០១៦។ និង "បុព្វហេតុនៃមរណៈមាតានិងកុមារក្នុងចំណោមអ្នកផ្តល់សេវាផ្លូវភេទនិងកូនរបស់ពួកគេ៖ ការសិក្សាឆ្លងវិស័យ" ដោយ by Brian Willis, Saki Onda, និង Hanni Marie Stoklosa, BMC Public Health, ថ្ងៃទី២៦ ខែវិច្ឆិកា ២០១៦

# មាត្រា 7

# ឧបសគ្គក្នុងការចូលរួមក្នុងវិស័យនយោបាយ និងជីវភាពសាធារណៈ គួរត្រូវបានលុបបំបាត់

## ការប្រឈមសម្រាប់អ្នកបោះឆ្នោតជាស្ត្រី

### ១.ការបាត់បង់លំហសិទ្ធិពលរដ្ឋ

បង្កជាបញ្ហាប្រឈមមួយ ចំពោះការចូលរួមនយោបាយរបស់ស្ត្រីនៅគ្រប់កម្រិត។ ក្នុងឆ្នាំ ២០១៧ រដ្ឋាភិបាលបានរារាំងបុគ្គលមួយចំនួនមិនឲ្យធ្វើដំណើរមកពីតាមខេត្តបានចូលឆែកឆេរនៅតាមការិយាល័យរបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន និងបិទចរាចរណ៍ដើម្បីរារាំងលទ្ធភាពនៃការតវ៉ានយោបាយ ឬសកម្មនិយមនយោបាយជាពិសេស នៅថ្ងៃទី ១៥ និង ១៦ ខែវិច្ឆិកា មុនពេលការចេញសេចក្តីសម្រេចរបស់តុលាការ ស្តីពីការរំលាយគណបក្សប្រឆាំង។ ប្រការនេះបណ្តាលឲ្យស្ត្រីមានការ ភ័យខ្លាចក្នុងការប្រើប្រាស់សិទ្ធិនយោបាយរបស់ខ្លួនដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយព្រមទាំងបានដាក់គំនាបទៅលើពួកគេឲ្យសម្របអាកប្បកិរិយានិងការបញ្ចេញមតិឲ្យត្រូវតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋាភិបាល។

### ២.ការចុះឈ្មោះអ្នកបោះឆ្នោត (ជាពិសេសសម្រាប់កម្មករចំណាកស្រុក)

គណៈកម្មាធិការរៀបចំការបោះឆ្នោតបានបំពេញការងារយ៉ាងល្អក្នុងការចុះឈ្មោះក្នុងបញ្ជីដែលចំនួនស្មើគ្នារវាងស្រី និងបុរសនៅតាមតំបន់ជាច្រើនក្នុងប្រទេសកម្ពុជាទាន់ពេលវេលា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ កាលពីឆ្នាំ ២០១៧ ។ ឧបសគ្គមួយដែលអ្នកបោះឆ្នោតជាស្ត្រីជួបប្រទះក្នុងការបោះឆ្នោតឃុំ-សង្កាត់ គឺប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានអនុវត្តដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងឆ្នាំ២០១៦។ ក្រោមក្របខណ្ឌនេះ មិនមានបទបញ្ញត្តិណាមួយដែលត្រូវបានដាក់បញ្ចូលអំពីការចុះឈ្មោះកម្មករចំណាកស្រុកកម្ពុជាដែលកំពុងរស់នៅបរទេសនោះទេ។ ជាងនេះទៀត ការបោះឆ្នោតដោយអវត្តមានមិនត្រូវបានអនុញ្ញាតទេ ទោះជាក្នុងប្រទេសកម្ពុជាក៏ដោយ។ ចំណុចនេះបង្កបញ្ហាជាច្រើនសម្រាប់ ស្ត្រីកម្ពុជាដោយសារតែស្ត្រីភាគច្រើនបានចំណាកស្រុកទៅក្រៅខេត្តរបស់ខ្លួននិងទៅបរទេសដើម្បីធ្វើការងារ។ មានការប៉ាន់ស្មានថាប្រជាជនកម្ពុជាប្រហែលមួយលាននាក់ដែលក្នុងនោះពាក់កណ្តាលជាស្ត្រីកំពុងធ្វើការនៅក្នុងប្រទេសដទៃទៀតជា កម្មករចំណាកស្រុក។ ពីរលាននាក់ផ្សេងទៀតដែលមានពាក់កណ្តាលជាស្ត្រីកំពុងរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ប៉ុន្តែមានសញ្ជាតិកម្ពុជាហើយនឹងមានសិទ្ធិបោះឆ្នោតប្រសិនបើពួកគេមានអាស័យដ្ឋាននៅកម្ពុជា។ការចំណាយសម្រាប់ការធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាជាច្រើនដង ដើម្បីទទួលបានអត្តសញ្ញាណប័ណ្ណ ដើម្បីចុះឈ្មោះបោះឆ្នោតនិងដើម្បីបោះឆ្នោត ដោយផ្ទាល់នោះ គឺមិនអាចជំនះបានទេ សម្រាប់ប្រជាជនកម្ពុជាភាគច្រើនដែលកំពុងរស់នៅក្រៅប្រទេស។

### ៣. ការទៅកាន់ការិយាល័យបោះឆ្នោត

ក្នុងឆ្នាំ២០១៧ ខុសពីការបោះឆ្នោតមុនៗ ដែលរដ្ឋាភិបាលដាក់កំណត់ថាទាំងថ្ងៃបោះឆ្នោត និងទាំងថ្ងៃមុនបោះឆ្នោត គឺត្រូវបានកំណត់យកជាថ្ងៃឈប់សម្រាកដែលបានទទួលបានប្រាក់ឈ្នួលកម្មករមិនបានទទួលការធានាអំពីពេលវេលាឈប់សម្រាកណាមួយក្នុងការបោះឆ្នោតនោះទេ។ កម្មករកាត់ដេរជាស្ត្រី ដែលភាគច្រើនជាកម្មករចំណាកស្រុកនៅក្នុងប្រទេសនេះ ត្រូវជ្រើសរើសរវាងការបាត់បង់ប្រាក់កម្រៃ និងការវិលត្រឡប់ទៅផ្ទះដើម្បីបោះឆ្នោត។

### ៤. ទំនៀមយេនឌ័រតាមប្រពៃណី

ទំនៀមយេនឌ័រតាមប្រពៃណី បានផាត់ស្ត្រីចេញមិនត្រឹមតែពីការចូលរួមក្នុងវិស័យនយោបាយក្នុងនាមជាបេក្ខជនប៉ុណ្ណោះទេ គឺថែមទាំងផាត់ចេញពីការចូលរួមក្នុងនាមជាអ្នកបោះឆ្នោតទៀតផង។ គេរំពឹងថាស្ត្រីត្រូវអនុញ្ញាតិឲ្យបុរសជាអ្នកដឹកនាំគ្រួសារ ក្នុងការសម្រេចចិត្តចម្បងៗទាំងអស់។ ជាលទ្ធផល ស្ត្រីមួយចំនួនទំនងជាអាចបណ្តោយឲ្យបុរសនៅក្នុងគ្រួសារធ្វើការសម្រេចចិត្តផ្នែកនយោបាយសម្រាប់គ្រួសារទៀតផង ដូចជាថាតើស្ត្រីគួរទៅបោះឆ្នោតឬទេហើយនិងថាតើគួរបោះឆ្នោតឲ្យគណបក្សណាមួយទៀតផង។

## ឧបសគ្គចំពោះបេក្ខជនជាស្ត្រី

ចំនួនស្ត្រីនៅក្នុងវិស័យនយោបាយ/តួនាទីនៅថ្នាក់ក្រោមជាតិបានថយចុះនៅក្នុងឆ្នាំ២០១៧ បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់។ ក្រោយការបោះឆ្នោតថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ យោងតាមទិន្នន័យរបស់ គ.ជ.ប[38] តំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់បានថយចុះ១% ពីឆ្នាំ២០១២។ ក៏ប៉ុន្តែ ចំនួនស្ត្រីជាមេឃុំ បានកើនឡើងដល់ ១២៨នាក់ ក្នុងចំណោមឃុំសង្កាត់ចំនួន ១៦៤៦ ក្នុងឆ្នាំ២០១៧ ពីចំនួន ៩៥នាក់ ក្នុងចំណោមឃុំសង្កាត់ចំនួន ១៦៣៣ ក្នុងឆ្នាំ២០១២។ នេះជាការកើនឡើងពី ៥,៨% ទៅ ៧,៧%។

38 គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បោះផ្សាយឯកសារជាភាសាខ្មែរ ដែលមានព័ត៌មានបែងចែកតាមយេនឌ័រមួយចំនួនសម្រាប់ការបោះឆ្នោតដោយរួមមានទាំងបញ្ជីឈ្មោះអ្នកបោះឆ្នោត បញ្ជីឈ្មោះបេក្ខជន និងលទ្ធផលបោះឆ្នោត នៅលើគេហទំព័រ https://www.necelect.org.kh/khmer/

## ១. គោលនយោបាយរដ្ឋាភិបាល ទាក់ទងនឹងស្ត្រីក្នុងមុខតំណែង

ប្រទេសកម្ពុជា ហាក់ដូចជាបានទទួលផលយឺតពីតំណាងរបស់ស្ត្រី ប៉ុន្តែបើយោងតាមផែនការនារីរតនៈវាហាក់ដូចជា យឺតជាងការគ្រោងទុកចំនួន១០ឆ្នាំ។ បន្ទាប់ពីអនុម័តផែនការនារីរតនៈទី៤ មិនយូរប៉ុន្មានស្ត្រីត្រូវបានតែងតាំងក្នុងតំណែងអភិបាល រងខេត្តទាំង២៤ ដែលនៅពេលនោះមានចំនួន២០% នៃតំណែងអភិបាលរងខេត្តសរុបចំនួន១១៩។ ក៏ប៉ុន្តែ រហូតដល់ ក្រោយការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ ទើបមានស្ត្រីម្នាក់ត្រូវបានតែងតាំងជាអភិបាលខេត្តមួយ[39]។ គោលបំណងដើម្បីជ្រើសរើសស្ត្រីនៅក្នុងមុខតំណែងត្រូវ

## ២. ប្រព័ន្ធបញ្ជីគណបក្ស

ក្នុងប្រទេសកម្ពុជាសន្លឹកឆ្នោតមានដាក់តែឈ្មោះគណបក្សប៉ុណ្ណោះ គឺមិនមានដាក់ឈ្មោះបេក្ខជនទេ។ ការជ្រើសរើសបេក្ខជនត្រូវអាស្រ័យទៅលើគណបក្សនយោបាយ ប៉ុន្តែបេក្ខជនទាំងនោះត្រូវតែបំពេញគ្រប់លក្ខខណ្ឌតម្រូវរបស់ គ.ជ.ប និងច្បាប់បោះឆ្នោតជាតិដើម្បីទទួលបានការអនុម័ត។ គណបក្សនិមួយៗមានបញ្ជីឈ្មោះបេក្ខជនសម្រាប់យុត្តាធិការនិមួយៗដោយរៀបតាមលំដាប់លេខរៀង។ ឈ្មោះនៅលើគេក្នុងបញ្ជីទទួលបានតំណែងមុនហើយអាសនៈដែលគណបក្សនយោបាយនិមួយៗទទួលបានបានតែទៅលើបេក្ខជន

| | គោលដៅ[40] | | ដាក់ស្តែង | | |
|---|---|---|---|---|---|
| | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍២០១៥ | នារីរតនៈ២០១៨ | ២០១៦ | ក្រោយការបោះឆ្នោតឃុំ សង្កាត់ ២០១៧ | ក្រោយការបែងចែកអាសនៈគណបក្សប្រឆាំង២០១៧[41] |
| ព្រឹទ្ធសភា | 30% | 30% | 14.75% | 14.75% | |
| រដ្ឋសភា | 30% | 30% | 20.33% | 20.33% | 15.% |
| តំណែងរដ្ឋមន្ត្រី | 15% | - | 10.70% | 10.70% | |
| រដ្ឋលេខាធិការ | 18% | - | 20.54% | 20.54% | |
| អនុរដ្ឋលេខាធិការ | 20% | - | 17.60% | 17.60% | |
| អភិបាលខេត្ត | 10% | - | 0% | 4% | |
| អភិបាលខេត្តរង | 15% | - | 20% | 20% | |
| អភិបាលស្រុក | | - | 1% | | |
| អភិបាលស្រុករង | | - | 29% | | |
| ក្រុមប្រឹក្សាឃុំសង្កាត់ | 25% | 25% | 17.78% | 16.76% | 21%( ដោយមាន43% នៃអាសនៈទាំងអស់នៅទំនេរ) |

បានដាក់ចេញខ្ពស់ ប៉ុន្តែមិនមានច្បាប់ ឬគោលនយោបាយសម្រាប់ជាវិធានការអនុវត្ត ដែលនាំអោយគណបក្ស នយោបាយទាំងអស់មិនបានប្រឹងប្រែងក្នុងការសម្រេចតាមគោលដៅនេះឡើយ។ ការបាត់បង់ឱកាសក្នុងការបញ្ចូលប្រព័ន្ធកូតាទៅក្នុងច្បាប់បោះឆ្នោតដែលត្រូវបានធ្វើវិសោធនកម្មថ្មីៗណាមួយនេះ ជាការឆ្លុះបញ្ចាំងអំពីការខ្វះនូវឆន្ទៈនយោបាយដើម្បីសម្រេចឲ្យបាននូវសមភាពយេនឌ័រពិតប្រាកដក្នុងអនាគតឆាប់ៗនេះ។

ដែលមានឈ្មោះនៅលំដាប់លើប៉ុណ្ណោះ។ ក្នុងប្រទេសកម្ពុជាមិនមានវិធានជាផ្លូវការ ឬ ច្បាប់ណាមួយដែលអនុវត្តតាមលក្ខខណ្ឌតម្រូវតាមរដ្ឋធម្មនុញ្ញក្នុងការបញ្ឈប់ការរើសអើងទៅលើស្ត្រីក្នុងការដាក់ឈ្មោះក្នុងបញ្ជីបេក្ខជនឡើយ។ ទោះបីជាវិធានបែបនេះអាចបញ្ចូលនៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយឬច្បាប់បង្កើតគ.ជ.ប[42] ក៏ដោយក៏ច្បាប់ទាំងពីរនេះត្រូវបានធ្វើវិសោធនកម្មលើសពីមួយដងនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ដោយគ្មានការដាក់បញ្ចូលបទបញ្ញត្តិ ក្នុងការលុបបំបាត់ការរើសអើងទៅលើស្ត្រីនៅក្នុងបញ្ជី

39 អូន ភាព ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២៩១៧ ឌឹ ខេមបូឌៀដេលី https://www.cambodiadaily.com/editorschoice/provincialgovernor-changes-draw-praise-disappointment-131462/

40 គោលដៅដែលកំណត់ក្នុងការឯកសារនារីរតនៈរបស់រដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។ សូមមើល https://sustainabledevelopment.un.org/sdgs for more information about SDGs in Cambodia.

41 Leonie Kijewski, "មានស្ត្រីតែពីរនាក់ប៉ុណ្ណោះចូលរួមក្នុងរដ្ឋសភា" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ វិច្ឆិកា ២០១៧

42 សង្គមស៊ីវិល ស្នើឲ្យមានការកំណត់កូតានិងផ្លាស់ប្តូរប្រព័ន្ធបញ្ជីឈ្មោះបេក្ខជន បន្ទាប់ពីការបោះឆ្នោត ប៉ុន្តែរដ្ឋាភិបាលមិនយល់ស្របទេ។ ពេជ្រ ចំរុង, "អង្គការចំនួន២៦និយាយថារដ្ឋាភិបាលខកខានក្នុងការបង្កើនចំនួនស្ត្រីក្នុងតួនាទីដឹកនាំ" VODHotnews.com, ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៧ (ភាសាខ្មែរ)។ ផ្ទុយមកវិញ រដ្ឋាភិបាលបង្ហាញសេចក្តីប្រាថ្នា ចង់លើកកម្ពស់ស្ត្រីក្នុងមុខងារសាធារណៈ។ ផែនការព្រាងមួយពីក្រសួងមុខងារសាធារណៈ មិនបានដាក់បញ្ចូលកូតាឬផ្លាស់ប្តូរនៅក្នុងគោលនយោ-បាយអំពីគុណវុឌ្ឍទេ ដូច្នេះវាមិនអនុលោមតាមអនុសាសន៍ទូទៅលេខ ២៥, កថាខណ្ឌ២៣ ស្តីពីវិធានការពិសេសបណ្តោះអាសន្ន។

ឈ្មោះបេក្ខជនដែរ។ ជាងនេះទៀត គណបក្សនយោបាយ មិនមានតម្លាភាពក្នុងការដាក់លេខរៀងបេក្ខជនទេ។ ជាលទ្ធផល ថ្នាក់ដឹកនាំគណបក្សដែលភាគច្រើនជាបុរស ត្រូវបានអនុញ្ញាតឲ្យតែងតាំងបុរសច្រើនជាងស្ត្រីនិងឲ្យដាក់ឈ្មោះបុរសនៅលេខរៀងខាងលើនៅក្នុងបញ្ជីនិងដាក់ឈ្មោះ ស្ត្រីនៅលេខរៀងខាងក្រោម។ ការអនុវត្តនេះ គឺប្រាកដណាស់ថាចំនួនភាគរយស្ត្រីដែលជាប់ឆ្នោតដឹងនៅតែមានអាត្រាទាប។

### ៣. ឧបសគ្គផ្នែកសេដ្ឋកិច្ចចំពោះការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ

ឧបសគ្គចម្បងមួយសម្រាប់បេក្ខជនជាស្ត្រី គឺថាទោះបីជាបានបង្ហាញភក្តីភាពចំពោះគណបក្ស និងមាន គុណវុឌ្ឍសម្រាប់ការងារក៏ដោយក៏ស្ត្រីនៅតែមិនអាចមានឈ្មោះនៅលេខរៀងខាងលើក្នុងបញ្ជីបេក្ខជនដែរប្រសិនបើមិនបានកៀងគរមូលនិធិច្រើនសម្រាប់ការធ្វើយុទ្ធនាការបោះឆ្នោតរបស់ខ្លួននោះទេ។ ស្ត្រីមានគុណវិបត្តិច្រើនធៀបនឹងបុរស ក្នុងការកៀងគរមូលនិធិ ដោយសារតែការបម្លាស់ទី និងចូលរួមបណ្តាញមានកម្រិត [43]។ ស្ត្រីមួយចំនួន ដោយមានការភ័យខ្លាចថាប្តី/គ្រួសាររបស់ពួកគេ មិនគាំទ្រយុទ្ធនាការនយោបាយរបស់ពួកគេបានខ្ចីប្រាក់កម្ចីដែលពួកគេសង្ឃឹមថានឹងអាចសងវិញបានក្រោយពេលទទួលបាន តួនាទីពីការបោះឆ្នោត[44] ។

ទោះបីជាគណបក្សមិនមានគោលនយោបាយជាលាយលក្ខណ៍អក្សរដែលតម្រូវឲ្យមានការរួមចំណែកផ្នែកហិរញ្ញវត្ថុក៏ដោយក៏ការខកខានមិនបានកៀងគរមូលនិធិប្រកបដោយប្រសិទ្ធភាពបានរារាំងស្ត្រី ពីការតម្លើងលេខរៀងនៅក្នុងបញ្ជីបេក្ខជន។

រដ្ឋាភិបាលនៅថ្នាក់ជាតិ ក៏មិនបានផ្តល់មូលនិធិណាមួយដើម្បីលើកទឹកចិត្តដល់បេក្ខភាព ស្ត្រីដែរ។ ជាងនេះទៀត មិនមានគណបក្សណាមួយមានគោលនយោបាយក្នុងការលើកទឹកចិត្តបេក្ខជនជាស្ត្រីទេផ្ទុយទៅវិញប្រព័ន្ធនេះបែរជាលើកកម្ពស់បក្សពួកនិយមនិងរឹតត្បិតមនុស្សថ្មីៗក្នុងការប្រកួតប្រជែងដើម្បីទទួលបានលេខរៀងខ្ពស់នៅក្នុងបញ្ជីបេក្ខជន។

### ៤. ផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រ

ស្ត្រីនិងបុរស ច្រើនតែត្រូវបានបង្រៀនថា ស្ត្រីមានភាពទន់ខ្សោយ និងមិនសក្តិសម នឹងតួនាទីជាអ្នកដឹកនាំគេទេ។ ជាលទ្ធផល មិនត្រឹមតែបុរសបង្ហាញភាពស្ទាក់ស្ទើរក្នុងការគាំទ្រដល់ស្ត្រីក្នុងវិស័យនយោបាយទេ ប៉ុន្តែសូម្បីតែស្ត្រីមួយចំនួនក៏ ខ្វះទំនុកចិត្តក្នុងការចូលរួមនៅក្នុងសកម្មភាពនយោបាយដែរ[45]។ ការធ្វើឲ្យមានតុល្យភាពរវាងការទទួលខុសត្រូវក្នុងគ្រួសារជាមួយនឹងនយោបាយក៏ជាបញ្ហាប្រឈមមួយសម្រាប់បេក្ខជនជាស្ត្រីដែរ។ អង្គការមិនមែនរដ្ឋាភិបាល មួយដែលធ្វើការជាមួយអ្នកនយោបាយជាស្ត្រីក្នុងគណបក្ស ផ្សេងៗគ្នាបានកត់សម្គាល់ថាស្ត្រីដែលបានចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលច្រើនឆ្នាំ ត្រូវបានសមាជិកគ្រួសាររិះគន់ នៅពេលដែលមិនមានអ្នកណាមើលការខុសត្រូវភារកិច្ចក្នុងគ្រួសារឬទៅលើកូន។ ស្វាមីមិនសប្បាយចិត្តនៅពេលដែលភរិយាចេញទៅក្រៅទេ ទោះបីជាមានការបណ្តុះបណ្តាលមួយចំនួនត្រូវបានរៀបចំឡើងសម្រាប់ស្វាមី ប៉ុន្តែស្វាមីមួយចំនួនក៏បានយល់ចេះដឹងក្នុងការគាំទ្រដល់ភរិយា តាមរយៈការមើលការខុសត្រូវកិច្ចការក្នុងគ្រួសារ និងថែទាំកូនដែរ[46]។

នៅពេលជាប់ឆ្នោតហើយ ស្ត្រីបន្តប្រឈមមុខនឹងការរើសអើងនិងឧបសគ្គចម្បងៗក្នុងការបំពេញតួនាទីរបស់ពួកគេ ឲ្យមានប្រសិទ្ធភាព ដោយសារតែឥរិយាបថរបស់អាជ្ញាធរ ដែលមិនគោរពសមត្ថកិច្ចរបស់មន្ត្រីជាស្ត្រី។ បុរសដែលធ្វើការជាមួយអ្នកនយោបាយស្ត្រីត្រូវការទទួលការបណ្តុះបណ្តាលដើម្បីបានយល់ដឹងអំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី និងការ ធ្វើសេចក្តីសម្រេចចិត្តសកម្ម។

បញ្ហាប្រឈមបន្ថែមមួយទៀតសម្រាប់អ្នកនយោបាយជាស្ត្រីនោះគឺថាប្រសិនបើពួកគាត់បានជាប់ឆ្នោតហើយ ពួកគាត់ ត្រូវគេរំពឹងថាត្រូវមានការទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាទាំងអស់ដែលប៉ះពាល់ជាពិសេសដល់ស្ត្រីនៅក្នុងសហគមន៍។ ឧទាហរណ៍ ប្រសិនបើស្ត្រីតែម្នាក់ដែលជាប់ជាក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយជាធម្មតានាងត្រូវបានគេផ្តល់តួនាទីជាតំណាងគណៈកម្មាធិការទទួលបន្ទុកលើកិច្ចការស្ត្រីនិងកុមារ។ដើម្បីឲ្យរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតស្ត្រីគួរត្រូវបានលើកទឹកចិត្តឲ្យទទួលខុសត្រូវកាន់តែធំជាងមុនក្រៅតែពីភារកិច្ចការផ្សេងៗក្រៅពីកិច្ចការផ្ទះហើយបុរសគួរត្រូវបានលើកទឹកចិត្តអោយទទួលខុសត្រូវធំជាងមុនសម្រាប់ការងារប្រើកំលាំង ចូលរួមនៅក្នុងបញ្ហានានា ដែលគេច្រើនតែចាត់ទុកថាជាក្តីបារម្ភរបស់ស្ត្រីដែរ។

**អនុសាសន៍៖**
អនុម័តច្បាប់មួយ ឬធ្វើវិសោធនកម្មច្បាប់ដែលមានជាធរមាន ដើម្បីតម្រូវឲ្យមានការដាក់ប្រព័ន្ធកូតាសម្រាប់ស្ត្រី នៅក្នុងថ្នាក់ដឹកនាំគណបក្សនយោបាយ និងនៅលើបញ្ជីបេក្ខជន។ តម្រូវឲ្យមានការដាក់ឈ្មោះបុរស និងស្ត្រីឆ្លាស់គ្នានៅលើបញ្ជី ដើម្បីធានាឲ្យមានការជ្រើសរើសមន្ត្រីជាស្ត្រីបានគ្រប់គ្រាន់ពិតប្រាកដ នឹងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រឹមឆ្នាំ២០៣០។

43 បញ្ហាប្រឈមនិងឱកាសផ្នែកហិរញ្ញវត្ថុ សម្រាប់បេក្ខជនជាស្ត្រីនៅក្នុងយុទ្ធសាស្ត្រឃោសនាបោះឆ្នោត៖ ការស្រាវជ្រាវករណីសិក្សាមួយពីប្រទេសកម្ពុជា, ខែកញ្ញា ២០១៧, អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា

44 បញ្ហាប្រឈមនិងឱកាសផ្នែកហិរញ្ញវត្ថុ សម្រាប់បេក្ខជនជាស្ត្រីនៅក្នុងយុទ្ធសាស្ត្រឃោសនាបោះឆ្នោត៖ ការស្រាវជ្រាវករណីសិក្សាមួយពីប្រទេសកម្ពុជា, ខែកញ្ញា ២០១៧, អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា

45 ការសម្ភាសន៍ជាមួយ USAID និងអង្គការបន្ទាយស្រី អង្គការដែលធ្វើការផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីដែលជាបេក្ខជនពីគ្រប់គណបក្សនយោបាយ ។

46 ការសម្ភាសន៍ជាមួយ USAID និងអង្គការបន្ទាយស្រី អង្គការដែលធ្វើការផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីដែលជាបេក្ខជនពីគ្រប់គណបក្សនយោបាយ ។

## មាត្រា 8

# ការធានាឲ្យមានតំណាងស្ត្រីនៅថ្នាក់អន្តរជាតិ

ទោះបីជាប្រទេសកម្ពុជាមានអ្នកដឹកនាំជាស្ត្រីដ៏រឹងមាំមួយចំនួនដែលតំណាងឲ្យប្រទេសកម្ពុជា នៅក្នុងកម្រិត អន្តរជាតិ ក៏ដោយក៏នៅតែគ្របដណ្តប់ភាគច្រើនដោយបុរសដែរ។ គេត្រូវការកិច្ចខំប្រឹងប្រែងខ្លាំងជាងនេះ ដើម្បីលើកកម្ពស់ស្ត្រីទៅក្នុងតួនាទីជាឯកអគ្គរាជទូត និងតួនាទីជាន់ខ្ពស់ផ្សេងទៀតនៅពេលទំនាក់ទំនងមួយដៃគូថ្នាក់ជាតិ និងថ្នាក់តំបន់។

## មាត្រា 9

# សញ្ជាតិ

ខណៈដែលច្បាប់ស្តីពីសញ្ជាតិ ផ្តល់សមត្ថភាពដូចគ្នាជាផ្លូវការដល់បុរសនិងស្ត្រី ក្នុងការបន្តផ្តល់សញ្ជាតិដល់កូន របស់ពួកគេនោះ ច្បាប់នេះមិនបានដោះស្រាយបញ្ហាទាក់ទងនឹងភាពគ្មានរដ្ឋនោះទេ[47]។ ដោយសារតែកំណើតនៅក្នុងប្រទេសកម្ពុជា មិនបានផ្តល់សញ្ជាតិដល់កូនដែលកើតមកនោះទេ លុះត្រាតែឪពុកម្តាយអាចផ្តល់ឯកសារទៅតាមដំណើរការផ្លូវច្បាប់[48] របស់ខ្លួន ដោយបង្ហាញថាគាត់មានសញ្ជាតិកម្ពុជា ស្ត្រីនិងកុមារីជាច្រើនដែលជានិគមជនវៀតណាម ប៉ុន្តែមានក្រុមគ្រួសារដែល បានបាត់បង់ឯកសារអត្តសញ្ញាណក្នុងអំឡុងពេលសង្គ្រាម ឬដែលបានរស់នៅដោយមិនមានឯកសារក្នុងប្រទេសកម្ពុជា ជាច្រើន ជំនាន់ហើយនោះ មិនមានសិទ្ធិទទួលបានសញ្ជាតិ ឬទទួលបានផលប្រយោជន៍សាធារណៈណាមួយនោះទេ។ អ្នកស្នាក់នៅដែលក្រីក្របំផុតជាច្រើននាក់ ដោយរាប់បញ្ចូលទាំងអ្នកដែលរស់នៅក្នុងភូមិនេសាទបណ្តែតទឹកនៅបឹងទន្លេសាបផងនោះស្ថិតនៅក្នុងស្ថានភាព ដែលមិនមានសញ្ជាតិវៀតណាម ឬសញ្ជាតិកម្ពុជាឡើយ ដែលកាន់តែធ្វើឲ្យពួកគេជាប់ផុងនៅក្នុងវដ្តនៃ ភាពក្រីក្រ។

ជាងនេះទៀតយោងតាមអនុក្រឹត្យចេញក្នុងខែសីហា ឆ្នាំ ២០១៧ រដ្ឋាភិបាលកម្ពុជាបានលុបចោលឯកសារសញ្ជាតិចេញពីប្រជាជន ដែលជានិគមជនវៀតណាមច្រើនជាង ១០.០០០នាក់[49]។ ក្រសួងមហាផ្ទៃ បានផ្តោតទៅលើមនុស្សចំនួន ៧០.០០០នាក់ ដែលត្រូវដកសញ្ជាតិចេញ ហើយក្នុងនោះ ៩០%ជាង ជានិគមជនវៀតណាម។ នាយកដ្ឋានអន្តោប្រវេសន៍ បានទទួលស្គាល់ថា ភាគច្រើននៃមនុស្សទាំងនេះមិនមានសញ្ជាតិណាផ្សេងទៀតទេ ប៉ុន្តែនឹងចាត់ទុកពួកគេដូចជនអន្តោប្រវេសន៍ក្នុងពេលអនាគត [50] ។

47 ច្បាប់ស្តីពីសញ្ជាតិ មាត្រា៤(១)

48 ច្បាប់ស្តីពីសញ្ជាតិ មាត្រា៤(២) លក្ខខណ្ឌតម្រូវសម្រាប់ការទទួលបានសញ្ជាតិ ទាមទារឲ្យមានការបង់លុយជាច្រើន (មាត្រា១០-១២) ឬ ទាមទារឲ្យមានការចេះអក្សរខ្មែរនិងមានឯកសារចាំបាច់ជាច្រើន (មាត្រា៨)។

49 ផក់ សៀងលី, "ឯកសារនិគមជនវៀតណាមច្រើនជាង១៧០០នាក់ ត្រូវបានដកហូត" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ 49 http://phnompenhpost.com/national/more-1700-ethnic-vietnamese-families-documents-taken

50 គង់ មេត្តា, "ក្រសួងមហាផ្ទៃ កំណត់រកឃើញពលរដ្ឋ "មិនសមរម្យ" ចំនួន ៧០.០០០នាក់ ភាគច្រើនជានិគមជនវៀតណាម" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ http://www.phnompenhpost.com/national/interior-ministry-identifies-70000-improper-citizens-mostly-ethnic-vietnamese

## មាត្រា 10

# ការអប់រំផ្លូវការ និងវិជ្ជាជីវៈ ការទទួលបានព័ត៌មានសុខភាព និងការអប់រំផ្លូវភេទ

រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងលើការអប់រំ សម្រាប់ក្មេងស្រី និងការកាត់បន្ថយការបោះបង់ការសិក្សាសំរាប់សិស្សស្រី ។

១. សហគមន៍និងគ្រួសារ គឺជាឧបសគ្គចម្បងរបស់ក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នា ដោយសារការរំពឹងថា ក្មេងស្រីត្រូវគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រុមគ្រួសារ ហេតុដូច្នេះហើយត្រូវទៅធ្វើការនៅរោងចក្រ។ រដ្ឋាភិបាលបានធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈដើម្បីលើកទឹកចិត្តគ្រួសារឲ្យបញ្ជូនកូនស្រីទៅសាលារៀន ក៏ប៉ុន្តែរដ្ឋាភិបាលមិន បានដាក់កំហិតដាច់ខាតថាត្រូវតែមានវត្តមាននៅសាលារៀននោះទេ។ មិនមានការដាក់ទោសទណ្ឌដល់គ្រួសារណាដែលបដិសេធមិនព្រមបញ្ជូនកូនស្រីទៅសាលារៀននោះទេ។

២.ក្មេងស្រីដែលបោះបង់ការសិក្សាច្រើនតែទទួលរងការខូចខាតផ្នែកសេដ្ឋកិច្ច ដោយសារតែគេយល់ឃើញថាពួកគេជាកម្មករដែលគ្មានជំនាញនិងដោយសារតែពួកគេច្រើនក្លាយទៅជាកម្មករចំណាកស្រុក។ ចន្លោះពី៨០% ទៅ ៩០% នៃកម្មករ រោងចក្រកាត់ដេរ និង៣០% នៃកម្មករសំណង់ [51] គឺជាមនុស្សស្រី ដែលភាគច្រើនជាជនចំណាកស្រុកពីតំបន់ជនបទនៃប្រទេសកម្ពុជា។ ក្នុងនាមជាជនចំណាកស្រុក ពួកគេបន្តប្រឈមការរើសអើងក្នុងទម្រង់ដូចជាការទទួលបានប្រាក់កម្រៃទាបជាងបុរស ដោយសារតែមានបុរេគំនិតថា ពួកគេមិនសូវមានជំនាញ។

៣. សុវត្ថិភាពរបស់ក្មេងស្រី មិនត្រូវបានការពារនៅពេលដែលពួកគេធ្វើដំណើរទៅសាលារៀនទេ។ ក្មេងស្រីស្ថិតក្នុងសភាពហានិភ័យដែលអាចត្រូវគេប្លន់ ត្រូវគេបំពាន ត្រូវគេឆក់ ឬអាចជួបប្រទះអំពើហិង្សា នៅពេលពើបប្រទះនឹងអ្នកប្រើប្រាស់ថ្នាំញៀន។

**អនុសាសន៍៖**
រដ្ឋត្រូវផ្តល់ការឧបត្ថម្ភធនធានឲ្យបានពេញលេញដល់វិស័យអប់រំ និងដាក់កំហិតដាច់ខាតចំពោះការទៅរៀនក្នុងសាលារៀនសម្រាប់កុមារ។ ការធ្វើទង្វើនេះនឹងជួយដល់គ្រួសារក្រីក្រឲ្យមានលទ្ធភាពបញ្ជូនកូនរបស់ពួកគេទាំងអស់ទៅសាលារៀន។ ធ្វើដូចនេះក៏នឹងបន្ធូរបន្ថយគំនាបលើក្មេងស្រីក្នុងការបោះបង់ការសិក្សាដើម្បីគាំទ្រគ្រួសាររបស់ពួកគេ ដោយធ្វើការបានកម្រៃទាប ប៉ុន្តែត្រូវលះបង់អនាគតរបស់ខ្លួនទៅវិញ។

51 អង្គការនានាដែលស្រាវជ្រាវក្នុងវិស័យសំណង់ ក្នុងប្រទេសកម្ពុជា ប៉ាន់ប្រមាណថា ប្រហែល ២០-៤០% នៃកម្មករសំណង់ជាស្ត្រី

# មាត្រា 11

## សិទ្ធិការងារ រួមទាំងឱកាសស្មើគ្នារវាងស្ត្រីនិងបុរសនៅគ្រប់វិស័យ

NGO-CEDAWពិតជាថ្លែងអំណរគុណចំពោះការពង្រើកកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជូនដំណឹង ដល់កម្មករអំពីការអនុវត្តគោលនយោបាយមិត្តស្ត្រី នៅក្នុងច្បាប់ការងារបច្ចុប្បន្ន ដោយរួមទាំងការថែទាំកុមារផលប្រយោជន៍នានាដែលស្ត្រីមានផ្ទៃពោះនឹងទទួលបានហើយនឹងការបញ្ចប់គោលនយោបាយដែលមានលក្ខណៈរើសអើង នៅលើកិច្ចសន្យា និងការបញ្ចប់កុងត្រាការងារ ។ ប៉ុន្តែបញ្ហាជាក់លាក់ ដូចខាងក្រោមនេះនៅតែកើតមាន៖

### ១. ការរឹតត្បឹតទៅលើសេរីភាពក្នុងការជួបជុំ

ការរឹតត្បឹតទៅលើសេរីភាពក្នុងការជួបជុំនិងឧបសគ្គនានាក្នុងច្បាប់ស្តីពីសហជីព ក្នុងការបង្កើតសហជីពថ្មី បង្កជាការប្រឈមមួយចំពោះស្ត្រីដែលមានបំណងចង់បញ្ចុះបញ្ចូល និង/ឬបង្ហាញដើម្បីទទួលបានលក្ខខណ្ឌការងារប្រសើរជាងមុន។ អង្គការ NGO-CEDAW សូមផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពក្នុងការលុបបំបាត់ការរឹតត្បឹតទៅលើការចុះបញ្ជីសហជីព ដើម្បីឲ្យច្បាប់អនុលោមតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ៨៧ និង ៩៨ ដែលប្រទេសកម្ពុជាបានចុះសច្ចាប័នក្នុងឆ្នាំ ១៩៩៩។

វិស័យនានាដែលមានកម្លាំងការងារជាស្ត្រីជាប្រពៃណីទៅហើយនោះ ត្រូវបានគេផាត់ចេញ មិនឲ្យបង្កើតសហជីពជាផ្លូវការតាមផ្លូវច្បាប់ទេ។វិស័យទាំងនេះរួមមាន អ្នកធ្វើការក្រៅប្រព័ន្ធ មន្ត្រីរាជការគ្រូបង្រៀន និងអ្នកធ្វើការតាមផ្ទះ។

### ២. ប្រាក់ឈ្នួលអប្បបរមា

ប្រាក់ឈ្នួលអប្បបរមា មិនត្រូវបានកំណត់សម្រាប់គ្រប់វិស័យឡើយគឺសម្រាប់តែវិស័យកាត់ដេរប៉ុណ្ណោះ។ ខណៈដែលការអនុវត្តបែបនេះ បានជះឥទ្ធិពលទៅលើស្ត្រីមួយចំនួនធំក៏ដោយ ក៏នៅមិនទាន់គ្រប់គ្រាន់ដែរដោយសារតែស្ត្រីនៅទទួលបានប្រាក់ឈ្នួលទាបនៅក្នុងវិស័យសំណង់ និងវិស័យការងារដទៃទៀត។ ជាងនេះទៀត ដោយសារតែស្ត្រីច្រើនតែចំណាកស្រុកតែឯងទៅទីក្រុង ដើម្បីជួយឧបត្ថម្ភគាំទ្រដល់ក្រុមគ្រួសាររបស់ពួកគេពួក គេត្រូវការប្រាក់ឈ្នួលខ្ពស់ជាងនេះដើម្បីអាចទូទាត់ការចំណាយលើការរស់នៅបន្ថែមពីការរស់នៅបែកពីក្រុមគ្រួសារ និង ដើម្បីសល់ប្រាក់ផ្ញើទៅឲ្យក្រុមគ្រួសារនៅតាមខេត្ត។ ជាពិសេសនៅក្នុងឧស្សាហកម្មសំណង់ ស្ត្រីតែងធ្វើការដោយគ្មានកិច្ចសន្យាឡើយ។ ស្ត្រីត្រូវគេផ្តល់ការងារដែលមានប្រាក់ឈ្នួលទាប និងការងារដែលមានជំនាញតិចជាងបុរសដែលមានការបណ្តុះបណ្តាលនិងបទពិសោធន៍តិចតួចដែរ។ដើម្បីដោះស្រាយបញ្ហាទាំងនេះ អង្គការ NGO-CEDAW សូមផ្តល់អនុសាសន៍ឲ្យមានការអនុម័តប្រាក់ឈ្នួលអប្បបរមាជា សាកល សម្រាប់កម្មករទាំងអស់គ្រប់ឧស្សាហកម្ម។ ជាងនេះទៀត ប្រទេសកម្ពុជាគួរផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ១៨៩ ស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករធ្វើការតាមផ្ទះ និងផ្តល់សច្ចាប័នទៅលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករចំណាកស្រុកនិងសមាជិកគ្រួសាររបស់ពួកគេ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាក្នុង ឆ្នាំ២០០៤ រួចហើយ។

### ៣. និយោជកប្រើប្រាស់កិច្ចសន្យារយៈពេលខ្លីដោយខុសច្បាប់

និយោជកប្រើប្រាស់កិច្ចសន្យារយៈពេលខ្លីដោយខុសច្បាប់ ដើម្បីរើសអើងទៅលើស្ត្រីតាមរយៈការមិនបន្តកិច្ចសន្យា[52] ការងារជាមួយកម្មករដែលមានផ្ទៃពោះ[53] ។ ច្បាប់ស្តីពីការងារមានលក្ខខណ្ឌតម្រូវជាច្រើនដែលមានប្រយោជន៍ដល់ស្ត្រីប៉ុន្តែពុំត្រូវបានអនុវត្តទេ។ ឧទាហរណ៍ ច្បាប់តម្រូវឲ្យនិយោជកផ្តល់ប្រាក់សម្រាប់ការសម្រាកមាតុភាព[54]ចាត់ទុកការបញ្ឈប់ស្ត្រីពីការងារដោយសារការមានផ្ទៃពោះជាអំពើខុសច្បាប់ និងហាមឃាត់ការប្រើប្រាស់កិច្ចសន្យារយៈពេលខ្លីដែលមានការការពារតិចតួចចំពោះនិយោជិត ប្រសិនបើពួកគេបានធ្វើការឲ្យក្រុមហ៊ុនអស់រយៈពេលពីរឆ្នាំឬលើសពីនេះ។ក្នុងការអនុវត្តជាក់ស្តែងរោងចក្រជាច្រើនមានទម្លាប់ប្រើកិច្ចសន្យារយៈពេលខ្លី សម្រាប់បុគ្គលិកទាំងអស់ដោយមិនខ្វល់ថាពួកគេធ្វើការបានរយៈពេលប៉ុន្មានហើយនោះទេ ហើយបានបញ្ឈប់ស្ត្រីមានផ្ទៃពោះនៅគ្រា ណាមួយមុនពេលទារកកើត ដើម្បីទប់ស្កាត់ការផ្តល់ដល់ស្ត្រីទាំងនោះនូវម៉ោងការងារខ្លីជាងធម្មតា ផ្តល់ការស្នាក់នៅសម្រាប់ការមានផ្ទៃពោះនិងផលប្រយោជន៍ផ្សេងៗទៀតសម្រាប់ការសម្រាកមាតុភាពជាដើម[55] ដោយសារតែវិស័យកាត់ដេរ និងវិស័យមួយចំនួនទៀត ប្រើប្រាស់អាជ្ញាកណ្តាលជាជាងការប្រើប្រាស់តុលាការក្នុងការដោះស្រាយបណ្តឹង និងដោយសារតែនិយោជក អាចត្រួតត្រាក្នុងការអនុញ្ញាតឲ្យអ្នកណាទៅផ្តល់សក្ខីកម្មនោះ និយោជកក៏ជារឿយៗអាចអះអាងថា ស្ត្រីមានផ្ទៃពោះដែលត្រូវ បានបញ្ឈប់ពីការងារក្រោយធ្វើការងារអស់ជាច្រើនឆ្នាំហើយនោះ គឺដោយសារតែគុណភាពការងាររបស់ពួកគេមានការធ្លាក់ចុះភ្លាមៗ។ការផ្តល់សច្ចាប័នអនុសញ្ញាអង្គ

52 ច្បាប់ស្តីពីការងារ មាត្រា៦៧ ហាមឃាត់កិច្ចសន្យារយៈពេលខ្លីសម្រាប់និយោជិត ដែលធ្វើការច្រើនជាងពីរឆ្នាំ

53 រាជរដ្ឋាភិបាលចង្អុលបង្ហាញថា វាក្លាយជាការពិតសម្រាប់កម្មកររោងចក្រកាត់ដេរ មុនការបោះឆ្នោតលើកក្រោយ
ប៉ុន្តែវាមិនទាន់ច្បាស់ថានឹងកើតឡើងដោយរបៀបណាឬថាតើវិធានការនេះ នឹងប្រើសម្រាប់តែឆ្នាំ២០១៨ ឬនឹងបន្តជាអចិន្ត្រៃយ៍។
មានផែនការក្នុងការផ្តល់ការលើកលែងពន្ធសម្រាប់និយោជកដើម្បីបង់ថ្លៃការបង្កើនប្រាក់ ឈ្នួល៦% ( ពី$១៦០ ដល់$១៧០ ) ក្នុងមួយខែ
ចំណុចនេះមិនមែនជាដំណោះស្រាយរយៈវែង។

54 ច្បាប់ស្តីពីការងារមាត្រា១៨២-១៨៣ ផ្តល់ដល់ស្ត្រីនូវការសម្រាកលំហែមាតុភាពចំនួន៩០ថ្ងៃ ដោយបានទទួលប្រាក់ខែពាក់កណ្តាល, ហាមឃាត់ការបញ្ឈប់បុគ្គលិកក្នុងអំឡុងពេលនេះ និងតម្រូវឲ្យធ្វើតែការងារស្រាលៗសម្រាប់រយៈពីរខែបន្ទាប់ពីត្រឡប់មកធ្វើការ។

55 យុន ស៊ីនៀត និង Erin Handley "ការប្រើប្រាស់កិច្ចសន្យាខ្លីបានទុកអោយស្ត្រីជាកម្មការីរោងចក្រដែលមានពោះ ស្ថិតនៅក្នុងស្ថានភាពមួយមិនទៀងទាត់ " ភ្នំពេញប៉ុស្ត៍ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៨ ។ http://www.phnompenhpost.com/national-post-depth/how-short-term-contracts-are-putting-cambodias-pregnant-factory-workers

ការពលកម្មអន្តរជាតិលេខ ១៨៣ ស្តីពីការការពារមាតុភាពការដាក់ចេញនូវបទប្បញ្ញត្តិ ដើម្បីពង្រឹងការដាក់ទណ្ឌកម្មសម្រាប់ការខកខានមិនបានផ្តល់ផលប្រយោជន៍មាតុភាព និងការបន្ថែមយន្តការ ការិយាល័យបណ្តឹងពលរដ្ឋ ដែលនឹងធ្វើឲ្យកម្មករមានភាពងាយស្រួលក្នុងការជំនះទៅលើលក្ខខណ្ឌការងារ ក្រៅរង្វង់អាជ្ញាកណ្តាលដែលត្រួតត្រាដោយនិយោជក គឺជាការបង្ហាញអំពីការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការដោះស្រាយបញ្ហាទាំងនេះ។

### ៤. ការទទួលបានការថែទាំកូន[56]

ស្រ្តីដែលមានកូន គួរទទួលបានការថែទាំកូនប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង មិនមានទេ[57] ។

### ៥. លក្ខខណ្ឌការងារ និងសុវត្ថិភាពរបស់ស្រ្តីនៅកន្លែងការងារ

លក្ខខណ្ឌការងារ និងសុវត្ថិភាពរបស់ស្រ្តីនៅកន្លែងការងារមិនត្រូវបានធានាឡើយ។ មានការជាប់ពាក់ព័ន្ធជាពិសេស ទៅនឹងកម្មករសំណង់ កម្មកររោងចក្រកាត់ដេរ និងស្រ្តីពិការ។ ទោះបីជាច្បាប់ស្តីពីការងារចែងអំពីស្តង់ដារសុវត្ថិភាពមួយចំនួនក៏ដោយក៏រដ្ឋាភិបាលមិនមានសមត្ថភាពក្នុងការធ្វើអធិការកិច្ចនៅទីតាំងកាងារ និងពង្រឹងការអនុវត្តច្បាប់នេះបានទេ។ ជាងនេះទៀត ខណៈដែលអធិការកិច្ចអង្គការពលកម្មអន្តរជាតិ ចុះទៅរោងចក្រនិយោជកតែងបានដឹងជាមុនថាពេលណា អធិការកិច្ចមកដល់ហើយពួកគេតែងតែបានរៀបចំរោងចក្រសម្រាប់ការចុះមកទស្សនកិច្ចនោះ។ ឧទាហរណ៍ និយោជកនៅ រោងចក្រកាត់ដេរមួយ អាចស្នើឲ្យបុគ្គលិកឈប់សំរាកនៅផ្ទះ ដើម្បីកុំឲ្យរោងចក្រមានភាពកកកុញណែនចង្អៀតនៅថ្ងៃដែលគេចុះទៅធ្វើទស្សនកិច្ចនោះ។បរិក្ខារបង្គន់មានសភាពមិនគ្រប់គ្រាន់និងមិនស្អាតទាល់តែសោះ(នៅក្នុងរោងចក្រនិងអន្តេវាសិកដ្ឋានមួយ ចំនួន បង្គន់មួយសម្រាប់ស្រ្តី១០០នាក់)។

ជារឿយៗ ស្រ្តីនៅក្នុងវិស័យកាត់ដេរ រស់នៅក្នុងលំនៅដ្ឋានមិនគ្រប់ស្តង់ដារ ដោយម្ចាស់ផ្ទះដែលបង្កើនថ្លៃជួលនៅពេលដែលប្រាក់ឈ្នួលអប្បបរមាកើនឡើងនោះ បានទាមទារថ្លៃទឹកថ្លៃភ្លើងហួសហេតុព្រមទាំងមិនបានផ្តល់ការដាក់ភ្លើងបំភ្លឺ ឲ្យមានសុវត្ថិភាព ឬមានអនាម័យនោះទេ។

សម្រាប់ស្រ្តីធ្វើការនៅក្នុងឧស្សាហកម្មសំណង់ការបារម្ភជាចម្បង គឺអំពើហិង្សាផ្លូវភេទ និងកង្វះឯកជនភាព ដោយសារតែជាញឹកញយ ពួកគេត្រូវដេកនៅក្រៅការដ្ឋានសំណង់[58]។ ស្រ្តីក៏ត្រូវប្រើប្រាស់បន្ទប់ទឹករួមជាមួយបុរសដែរ(ប្រសិនបើមានការផ្តល់បន្ទប់ទឹកឲ្យប្រើប្រាស់នោះ)។

### ៦. ការរើសអើងទៅលើស្រ្តីពិការ

មិនមានការកំណត់ស្តង់ដារណាមួយនៅកន្លែងធ្វើការ និងនៅកន្លែងសាធារណៈ សម្រាប់ជនពិការទេ។អាគារនិងកន្លែងធ្វើការសាធារណៈនិងឯកជនភាគច្រើនមិនបង្ករលក្ខណៈងាយស្រួលសម្រាប់កៅអីរុញនោះទេ។ប្រព័ន្ធកូតាដែលគាំទ្រដោយរដ្ឋាភិបាលមិនត្រូវបានពង្រឹងការអនុវត្តឲ្យបានល្អនោះទេ[59] ។

### ៧. ការយាយីរំខានផ្លូវភេទ

ការយាយីរំខានផ្លូវភេទនៅកន្លែងធ្វើការត្រូវបានរកឃើញដោយកម្មករថា ជាបញ្ហាដែលចម្បង និងកើតឡើងជាប់លាប់។ មានច្បាប់តិចតួចណាស់នៅកម្ពុជាដែលដោះស្រាយបញ្ហានេះដោយផ្ទាល់ហើយវាក៏មិនបានកំណត់និយមន័យនៅក្នុងច្បាប់របស់ប្រទេសកម្ពុជាដែរដូច្នេះជាការលំបាកក្នុងការដាក់ទណ្ឌកម្មដល់និយោជកដែលបណ្តោយឲ្យមានការយាយីរំខាននេះ[60]។ ជាងនេះទៀតមានការខ្វះខាតការយល់ដឹងជាទូទៅមួយក្នុងចំណោមបុគ្គលិកកម្មករអំពីបញ្ហានិងនិយមន័យនៃការយាយីរំខានផ្លូវភេទ។ សូម្បីតែអ្នកខ្លះដែលបានចូលរួមនៅក្នុងការបណ្តុះបណ្តាលអំពីការយាយីរំខានផ្លូវភេទមិនទាន់បានយល់ច្បាស់នៅឡើយទេ អំពីភាពខុសគ្នារវាងការបំពានផ្លូវភេទ និងការយាយីរំខានផ្លូវភេទនៅឡើយ។ កង្វះខាតចំណេះដឹងអំពីបញ្ហានេះ បានរារាំងមិនឲ្យមានភាពល្អប្រសើរឡើងនូវបញ្ហាដែលកើតឡើងឡើយ។ខណៈដែលរដ្ឋាភិបាលអាចទទួលបាននូវការកោតសរសើរតាមរយៈការចេញសេចក្តីប្រកាសស្តីពីអ្នកធ្វើការក្នុងវិស័យកំសាន្តដោយបានហាមឃាត់អំពើ" ដែលប្រើប្រាស់ហិង្សា និងមិនសមរម្យ"នោះ ប្រកាសនោះមិនបានកំណត់និយមន័យឬប្រើប្រាស់ពាក្យ ការយាយីរំខានផ្លូវភេទ"ទេ។ជាងនេះទៀតក៏មិនមានយន្តការច្បាស់លាស់សម្រាប់កម្មករ រាយការណ៍ឬដាក់ពាក្យបណ្តឹងនោះទេ។

### ៨. ពលកម្មកុមារ

ការប្រើប្រាស់ពលកម្មកុមារកំពុងកើនឡើងនៅក្នុងប្រទេសកម្ពុជាដែលជាលទ្ធផលមួយផ្នែកនៃការកើនឡើងនូវការជំពាក់បំណុល។ ដំបូងគ្រួសារទទួលកម្ចីពីធនាគារ នៅតំបន់ជនបទបន្ទាប់មកបំណុលនេះត្រូវបានម្ចាស់ឡតដ្ឋទិញយក[61] ។ ជារឿយៗកម្មករត្រូវជាប់នៅក្នុងរង្វង់នៃការធ្វើការងារជាប្រចាំ ដោយមិនអាចសងបំណុលនោះរួចឡើយ។ការប៉ុនប៉ងចាកចេញពីការដ្ឋានការងារអាចបណ្តាលឲ្យមានការគំរាមកំហែងចាប់ខ្លួននិងដាក់ពន្ធនាគារ។

**អនុសាសន៍៖**
អនុម័តប្រាក់ឈ្នួលអប្បបរមាជាសាកល និងពង្រឹងការអនុវត្តច្បាប់ស្តីពីការងារឲ្យបានកាន់តែល្អ ប្រសើរ។ អនុម័តអនុសញ្ញាអង្គការពលកម្មអន្តរជាតិនិងអង្គការសហប្រជាជាតិ ដើម្បីការពារកម្មករចំណាកស្រុកនិងកម្មករធ្វើការតាមផ្ទះ។

56 ច្បាប់ស្តីពីការងារមាត្រា១៨៤-១៨៥ តម្រូវឲ្យមានពេលនិងកន្លែងសម្រាប់បំបៅដោះកូនក្នុងអំឡុងពេលម៉ោងធ្វើការ។ មាត្រា១៨៦ តម្រូវឲ្យមានមណ្ឌលថែទាំមួយសម្រាប់និយោជកធំៗ។

57 Hannah Hawkins, " កម្មវិធីអភិវឌ្ឍន៍របស់ប្រទេសបារាំង ក្នុងការបង្កើតទារកដ្ឋានសម្រាប់កម្មការីរោងចក្រ " ខេមបូឌាដេលី ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ ។ https://www.cambodiadaily.com/news/french-project-to-set-up-day-care-services-for-factory-workers-132702/

58 របាយការណ៍ប៉ាន់ប្រមាណគម្រោងដោយអង្គការ CARE Cambodia ឆ្នាំ ២០១៦ "សិទ្ធិការងាររបស់ស្រ្តីកម្មករសំណង់" ។

59 David Hutt, "Failure to enforce jobs quota law shortchanges Cambodia's disabled" Southeast Asia Globe, 26 April 2016. http://sea-globe.com/lack-enforcement-cambodia-disabled-law/

60 ការស្រាវជ្រាវដោយ ACILS អង្គការដែលធ្វើការជាមួយ សហជីព និងកម្មករ ។

61 របាយការណ៍អង្គការលីកាដូ៖ ការអភិវឌ្ឍន៍លើទាសភាព, ឆ្នាំ២០១៦
LICADHO report: "Built on Slavery, Debt Bondage and Child Labour in Cambodia's Brick Factories," December 2016

# មាត្រា 12

# ការទទួលបានការថែទាំសុខភាព

រដ្ឋាភិបាល បានធ្វើអោយមានការប្រសើរឡើងជាច្រើនចំពោះសមភាព និងការដែលអាចទទួលយកបាននូវសេវាថែទាំសុខភាពនៅក្នុងឆ្នាំដែលកន្លងទៅថ្មីៗនេះ ជាពិសេសផ្តល់ការព្យាបាលដល់អ្នកផ្ទុកមេរោគហ៊ីវ និងអ្នកផ្ទុកមេរោគអេដស៏។ ភាគច្រើននៃអ្នកផ្ទុកមេរោគហ៊ីវ និងអ្នកជំងឺអេដស៏ដឹងពីស្ថានភាពជំងឺរបស់ពួកគេនិងទទួលបានការព្យាបាលតាមបែបវេជ្ជសាស្ត្រ។ តែទោះជាបែបនេះក្តី ការកែលំអរបន្ថែមនៅតែចាំបាច់តាមផ្នែកផ្សេងៗដទៃទៀត ។

## ១. ការទទួលបានការថែទាំសុខភាពជាទូទៅ

ស្ត្រី ជាពិសេសស្ត្រីមានផ្ទៃពោះ មិនបានទទួលការថែទាំសុខភាពគ្រប់គ្រាន់នោះទេ។ កង្វះសេវាសុខភាពនៅតំបន់ជនបទក៏ជាក្តីបារម្ភពិសេសមួយដោយសារតែមន្ទីរពេទ្យមណ្ឌលសុខភាព និងគ្លីនីក ស្ថិតនៅឆ្ងាយពីផ្ទះរបស់ស្ត្រី។ សម្ភារៈបរិក្ខារថែទាំសុខភាពមិនមានធនធានសម្រាប់បើកទទួលអ្នកជំងឺនៅគ្រប់ពេលដែលត្រូវការចាំបាច់បំផុតនោះទេ។ បុគ្គលិកធ្វើការ តិចម៉ោងហើយមណ្ឌលសុខភាពអាចបិទនៅចុងសប្តាហ៍និងពេលល្ងាចដូច្នេះពួកគេមិនអាចផ្តល់សេវាគ្រប់គ្រាន់ដល់អ្នកជំងឺទេជាពិសេស ផ្តល់សេវាដល់ស្ត្រី។

ជាងនេះទៀត មិនមានការឃ្លាំមើលណាមួយ ដើម្បីធានាគុណភាពថែទាំដែលបានផ្តល់នោះទេ។ មិនមានការការពារ ណាមួយប្រឆាំងនឹងការអនុវត្តផ្នែកវេជ្ជសាស្ត្រដែលមិនបានត្រឹមត្រូវទេ។

## ២. សុខភាពបន្តពូជ

ស្ត្រីភាគច្រើន មិនទទួលបានព័ត៌មានគ្រប់គ្រាន់អំពីសិទ្ធិសុខភាពបន្តពូជរបស់ខ្លួនឡើយ។ ទោះបីជារដ្ឋមានកម្មវិធីសិក្សាថ្មីមួយ និងសម្ភារៈបណ្តុះបណ្តាលស្តីពីសុខភាពបន្តពូជដោយរាប់ទាំងការពន្យារកំណើត និងជំងឺកាមរោគក៏ដោយ ក៏មុខវិជ្ជាមួយនេះជារឿយៗមិនមានបង្រៀននៅក្នុងសាលាឬនៅក្នុងមជ្ឈមណ្ឌលសហគមន៍ទេ។ គ្រួសារភាគច្រើនមានការអៀនខ្មាស់ក្នុងការពិភាក្សាលើប្រធានបទទាំងនេះ។ប្រការនេះធ្វើឲ្យក្មេងស្រីមានហានិភ័យខ្ពស់ចំពោះការមានផ្ទៃពោះក្នុងវ័យជំទង់[62]។ តាមច្បាប់ ក្មេងស្រីមិនអាចធ្វើការសម្រេចចិត្តអំពីការរំលូតកូនទេ រហូតដល់ពួកគេមានអាយុ១៨ឆ្នាំ ហើយស្ត្រីជាច្រើនមានអារម្មណ៍ថាពួកគេមិនមានជម្រើសទេ ក្រៅតែពីសមាជិកផ្សេងទៀតក្នុងគ្រួសារជាអ្នកធ្វើការសម្រេចចិត្តជំនួសពួកគេ។ មានអ្នកផ្តល់សេវាខុសច្បាប់ក្នុងការរំលូតកូន ប៉ុន្តែមានគ្រោះថ្នាក់សម្រាប់ក្មេងស្រី និងស្ត្រីដែលប្រើប្រាស់សេវាទាំងនោះ។

## ៣. អំពើហិង្សាលើយេនឌ័រនិងសុខភាព

ស្ត្រីដែលបានទទួលរងអំពើហិង្សាលើយេនឌ័រអាចស្វែងរកការថែទាំវេជ្ជសាស្ត្រនៅមន្ទីរពេទ្យឬនៅតាមមណ្ឌលសុខភាពប៉ុន្តែបុគ្គលិកមិនបានផ្តល់ការថែទាំសមរម្យ ឬបញ្ជូនទៅទទួលបានសេវាឯកទេសនានានោះទេ។ បុគ្គលិកមន្ទីរពេទ្យមួយចំនួន រិះគន់អ្នកជំងឺ ដែលសុខចិត្តទ្រាំចំពោះអំពើហិង្សាឬបណ្តោយឲ្យគេប្រើហិង្សាមកលើខ្លួន។ មានស្ត្រីតិចតួចណាស់ដែលត្រូវបាន គេសាកសួរអំពីតម្រូវការផ្នែកអារម្មណ៍និងផ្នែកផ្លូវចិត្តនៅពេលដែលពួកគេទៅស្វែងរកជំនួយចំពោះអំពើហិង្សាយេនឌ័រ។ ជារឿយៗគេមិនដែលពិភាក្សាអំពីសុខភាពផ្លូវចិត្តទេហើយស្ត្រីមិនបានទទួលការព្យាបាលសុខភាពផ្លូវចិត្តឲ្យបានគ្រប់គ្រាន់ដែរ។

## ៤. មេរោគហ៊ីវ/ជំងឺអេដស៍

ប្រទេសកម្ពុជាបានកែលម្អការព្យាបាលអ្នកផ្ទុកមេរោគហ៊ីវ/ជំងឺអេដស៍ ដោយសារការអាចរកថ្នាំបានជាទូទៅ។ ក៏ប៉ុន្តែមនុស្សជាច្រើននៅតែមិនទាន់ទទួលបានព័ត៌មានគ្រប់គ្រាន់អំពីការទប់ស្កាត់មេរោគហ៊ីវ/ជំងឺអេដស៍នេះនៅឡើយទេ។

## ៥. បញ្ហាដែលស្ត្រីងាយរងគ្រោះប្រឈម

ស្ត្រីអ្នកលក់ដូរតាមផ្លូវ ស្ត្រីអ្នកធ្វើការតាមផ្ទះ អ្នកស្រលាញ់ភេទដូចគ្នា( LGBTIQ ) ស្ត្រីពិការ និងស្ត្រីជនបទប្រឈមបញ្ហាជាក់លាក់មួយចំនួនក្នុងការទទួលបានការថែទាំសុខភាពដូចជា៖

ក. មិនអាចមានលទ្ធភាពក្នុងការបង់ថ្លៃព្យាបាលសុខភាព។ ស្ត្រីជាច្រើនមិនត្រូវបានឡានពេទ្យដឹកឬមន្ទីរពេទ្យផ្តល់សេវាឲ្យទេ ប្រសិនបើពួកគេមិនអាចបង្ហាញថាពួកគេមានការធានារ៉ាប់រងឬមានលុយដើម្បីបង់ថ្លៃសេវានោះ។ ស្ត្រីផ្សេងទៀត ដែលបានទទួលការថែទាំវេជ្ជសាស្រ្ត អាចជំពាក់បំណុលគេ ដោយសារតែការចំណាយ ខ្ពស់ជាងលទ្ធភាពដែលពួកគេអាចបង់បាន។

ខ. ការរើសអើងទៅលើស្ត្រី កើតឡើងនៅមន្ទីរពេទ្យសាធារណៈ ជារឿយៗដោយវេជ្ជបណ្ឌិត គិលានុបដ្ឋាកនិងបុគ្គលិកមន្ទីរពេទ្យដែលមិនបានបង្ហាញនូវភាពជាវិជ្ជាជីវៈក្នុងការផ្តល់សេវា។

ឧទាហរណ៍៖ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន រាយការណ៍ថាបុគ្គលិកពេទ្យជារឿយៗប្រមាថមាក់ងាយស្ត្រីដែលស្វែងរកការថែទាំរបួសដែលបង្កឡើងដោយអំពើហិង្សាលើយេនឌ័រ។ អ្នកផ្តល់សេវាថែទាំសុខភាពអាចនឹងបដិសេធមិនជួយដល់ស្ត្រីដែលគេសង្ស័យថាជាអ្នករកស៊ីផ្លូវភេទឬស្ត្រីដែលអះអាងថាត្រូវគេរំលោភ។

**អនុសាសន៍៖**

សេវាសុខភាពត្រូវតែផ្តល់ជូនដោយអត់បង់ថ្លៃនិងត្រូវមានគុណភាពខ្ពស់។ រាជរដ្ឋាភិបាលត្រូវតែបង្កើនកញ្ចប់ថវិកាសម្រាប់មន្ទីរពេទ្យរដ្ឋនិងមណ្ឌលសុខភាព។

62 លទ្ធផលនៃឧបករណ៍តាមដាន ពីអង្គការនានាដែលធ្វើការងារក្នុងវិស័យថែទាំសុខភាព ។

# មាត្រា 13 ផលប្រយោជន៍សេដ្ឋកិច្ច និងការចូលរួមក្នុងសង្គម និងវប្បធម៌

## ផលប្រយោជន៍

ខណៈដែលរដ្ឋាភិបាលមានប្រព័ន្ធក្នុងការផ្តល់ប័ណ្ណសម្គាល់ជនក្រីក្រ ដល់អ្នកមានប្រាក់ចំណូលទាបដែលជាសក្តានុពលយ៉ាងល្អ សម្រាប់អោយស្រ្តីទទួលបាននូវផលប្រយោជន៍ស្មើគ្នាពីរដ្ឋាភិបាល។ ក្នុងខណៈដែលអ្នកកាន់កាប់ប័ណ្ណ សម្គាល់ជនក្រីក្រនេះបានទទួលនូវសេវាថែទាំសុខភាព និងសេវាសង្គមផ្សេងៗទៀតនោះ ការចែកប័ណ្ណនេះនៅមិនទាន់បានគ្រប់គ្រាន់នៅឡើយទេ។ គ្រួសារដែលគួរមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានប័ណ្ណនេះ អាចមិនបានដឹងអំពីសិទ្ធិរបស់ខ្លួន អាចមិនបានដាក់ពាក្យសុំ ឬអាចត្រូវបានគេបដិសេធនៅពេលដាក់ពាក្យសុំ។ មិនមានប្រព័ន្ធសន្តិសុខសង្គមក្រៅតែពីប្រព័ន្ធ សោធននិវត្តន៍សម្រាប់តែមន្ត្រីរាជការមួយចំនួនតែប៉ុណ្ណោះទេ។ មូលនិធិរបបសន្តិសុខសង្គម មិនបានគ្របដណ្តប់លើគ្រប់វិស័យទេ ហើយក៏មិនបានពង្រឹងការអនុវត្តឲ្យបានទូលំទូលាយដែរ។ តាមទ្រឹស្តីជនពិការមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ ប៉ុន្តែតាមតថភាពជាក់ស្តែង ជារឿយៗ ពួកគេត្រូវបង្ខំចិត្តសុំទានតាមផ្លូវ ដើម្បីបានចំណូលខ្លះមកចិញ្ចឹមខ្លួន។

## ធនាគារ/ប្រាក់កម្ចី

ទោះបីជាមានធនាគារ ដែលផ្តល់ប្រាក់កម្ចីក៏ដោយ ក៏ប្រជាជនកម្ពុជាភាគច្រើន ខ្ចីលុយពីក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុដែលមិនមានច្បាប់ត្រឹមត្រូវ ហើយត្រូវបង់ការប្រាក់ខ្ពស់ខ្លាំង។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលនូវការកោតសរសើរ សម្រាប់ការណែនាំការកំណត់ទៅលើអត្រាការប្រាក់ថ្មីក្នុងឆ្នាំ២០១៧។ ក៏ប៉ុន្តែការប្រាក់អាត្រាថ្មីត្រឹម១៨% នៅតែខ្ពស់ពេកបើប្រៀបនឹងអាត្រាកំណើនសេដ្ឋកិច្ច។ គ្រួសារជាច្រើនមិនអាចបង់ថ្លៃប្រាក់កម្ចីវិញបានទេ។ បន្ថែមលើនេះ ការទទួលបានសូម្បីតែប្រាក់កម្ចីបែបនេះ ក៏នៅមានកម្រិតដែរ ដោយសារតែស្ថាប័នមីក្រូហិរញ្ញវត្ថុ មានលក្ខខណ្ឌតម្រូវខ្ពស់ ហើយស្រ្តីជាច្រើនមិនអាចបំពេញលក្ខខណ្ឌទាំងនោះ ដើម្បីទទួលបានប្រាក់កម្ចីឡើយ។ អ្នកដាក់ពាក្យសុំ ត្រូវមានប្រាក់ចំណូលដែលមានស្ថេរភាព ឬមានការងារល្អ។ប្រការនេះបង្កជាបញ្ហាប្រឈមមួយសម្រាប់ស្រ្តីដោយសារតែពួកគេច្រើនតែងធ្វើការនៅក្នុងវិស័យក្រៅផ្លូវការដូចជាកសិកម្មនេសាទ ឬធ្វើការជាអ្នកលក់ដូរនៅតាមផ្លូវ និងនៅតាមកន្លែងសាធារណៈផ្សេងៗទៀត។ ជួនកាលអ្នកដាក់ពាក្យសុំខ្ចីប្រាក់ត្រូវមានកម្មសិទ្ធិទ្រព្យសម្បត្តិ ហើយជារឿយៗស្រ្តីមិនមានឈ្មោះនៅក្នុងប័ណ្ណកម្មសិទ្ធិទេ។ ប្រសិនបើមានឈ្មោះរួមគ្នាប័ណ្ណកម្ម សិទ្ធិទ្រព្យសម្បត្តិនោះ ត្រូវមានហត្ថលេខាទាំងពីរនាក់នៅលើពាក្យស្នើសុំនោះ[63] ។ ទោះបីជាមានស្ថាប័នឯកជនមួយចំនួនគាំទ្រដល់សហគ្រិនជាស្រ្តីតាមរយៈការផ្តល់កម្មវិធីបង្វឹកហាត់ផ្តល់ប្រាក់កម្ចី និងផ្តល់ប្រាក់ជំនួយក៏ដោយ ក៏វាមិនមានជាលក្ខណៈទូលំទូលាយដែរ។

ស្រ្តីមានអំណាចក្នុងការសម្រេចចិត្តនៅក្នុងគ្រួសារច្រើនជាងពីមុន។ និន្នាការនេះ មានសភាពជាក់ច្បាស់ជាពិសេសនៅតាមទីក្រុង ដែលស្រ្តីមានការអប់រំល្អ។ ក្នុងគ្រួសារនៅតាមជនបទ ស្រ្តីនៅតែបន្តខ្វះអំណាចក្នុងការសម្រេចចិត្ត ដោយសារតែការពឹងផ្អែកទៅលើសមាជិកប្រុសនៅក្នុងគ្រួសារ [64] ។

## កីឡា

កម្ពុជាបានធ្វើអោយមានការរីកចម្រើន ដែលកីឡាការិនីអត្តពលិកតៃក្វាន់ដូ ស៊ន សៀវម៉ី ទទួលបានជ័យលាភីលើ ការប្រកួតហ្គេមអូឡាំពិកកាលពីឆ្នាំ ២០១៦ ។ ជាងនេះទៅទៀត រដ្ឋបានបង្កើតគណៈកម្មការលើកកម្ពស់ការចូលរួមរបស់ស្រ្តីក្នុងវិស័យកីឡា។ ទោះយ៉ាងណាក៏ដោយការរើសអើងនៅបន្តកើតមានទៅលើស្រ្តីដែលមានភាពសកម្មក្នុងវិស័យកីឡាក្រៅផ្ទះ ដូចជាស្រ្តីដែលលេងបាល់ទាត់ជាដើម។ បុរសជាច្រើនមិនយល់ថា ស៊ន សៀវម៉ី ជា“ស្រ្តីពិតប្រាកដ” នោះទេ។ ក៏ប៉ុន្តែ មានស្រ្តីតិចតួចប៉ុណ្ណោះ ជាសមាជិករបស់ក្រុមរបស់គណៈកម្មការដើម្បីលើកកម្ពស់ការចូលរួមរបស់ស្រ្តីក្នុងវិស័យកីឡា[65]។

63 ការសម្ភាសន៍ជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដែលធ្វើការជាមួយស្រ្តីនៅក្នុងប្រទេសកម្ពុជា ។ Asia Foundation
64 លទ្ធផលនៃឧបករណ៍តាមដានពីអង្គការនានាដែលធ្វើការជាមួយស្រ្តីជនបទ ។
65 ការសម្ភាសន៍ជាមួយអង្គការដែលធ្វើការជាមួយនឹងផ្ទត់គំនិតយេនឌ័រ

# មាត្រា 14

## ស្ថានភាពរបស់ស្ត្រីជនបទ

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត កម្មវិធីជាច្រើនក្នុងឆ្នាំកន្លងទៅ ជាពិសេសក្នុងការសហការណ៍ជាមួយអង្គការសង្គមស៊ីវិល ដើម្បីអោយការរស់នៅរបស់ស្ត្រីនៅតំបន់ជនបទមានភាពប្រសើរឡើង។ តែទោះជាយ៉ាងនេះក្តី ឧបសគ្គមួយចំនួននៅតែមាន។ ទោះបីអនាម័យមានភាពប្រសើរនៅទីក្រុងក៏ដោយក៏នៅតំបន់ជនបទនៅតែមានភាពទន់ខ្សោយនៅឡើយ។ គ្រួសារជាច្រើនមិនមានបរិក្ខារបង្គន់ហើយធ្វើដំណើរទៅតាមវាលជាពិសេសនៅពេលយប់ ដើម្បីបំពេញតម្រូវការ ផ្នែកអនាម័យ ដែលបង្កនូវហានិភ័យនៃអំពើហិង្សាដល់ស្ត្រី និងកុមារី។ អំពើហិង្សាលើយេនឌ័រជាបញ្ហាពិសេសមួយសម្រាប់ស្ត្រី និងកុមារីនៅតំបន់ជនបទ ជាពិសេសដោយសារតែធនធានជំនួយមានតិចតួច និងដោយសារតែផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រតាមបែបប្រពៃណី។ កសិកម្មគឺជា ប្រភពចំណូលដ៏សំខាន់សម្រាប់ស្ត្រីជនបទ។ ក៏ប៉ុន្តែមានការខ្វះខាត កម្មវិធីបណ្តុះបណ្តាលជំនាញដើម្បីបង្រៀនឲ្យមានជំនាញ និងបច្ចេកទេសកសិកម្មកាន់តែប្រសើរដល់ស្ត្រីជនបទ។ ស្ត្រីខ្វះខាតចំណេះ និងជំនាញអំពីរបៀបធ្វើឲ្យផលិតផលតាមរយៈវប្បធម៌ អាចយកទៅលក់បាន និងអំពីរបៀបធ្វើឲ្យផលិតកម្មមានលក្ខណៈស្តង់ដារ។បែបនេះអាចនឹងមានប្រយោជន៍ជាពិសេសសម្រាប់ស្ត្រីជនបទ ក្នុងការទទួលបានឱកាសបណ្តុះបណ្តាលដើម្បីលើកទឹកចិត្តដល់ឧស្សាហកម្មក្នុងស្រុកបង្កើនឯករាជ្យភាពផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងកាត់បន្ថយគំនាបក្នុងការជម្រុញអោយមានចំណាកស្រុក។

កង្វះព័ត៌មាន និងមធ្យោបាយក្នុងការបង្កើតបណ្តាញរវាងអ្នកទិញនិងអ្នកផ្គត់ផ្គង់ នេះគឺជាបញ្ហាបន្ថែម។ អ្នកទិញមានការលំបាកក្នុងការរកអ្នកលក់ នៅពេលដែលពួកគេចង់ទិញផលិតផលក្នុងស្រុកពីកសិករកម្ពុជា។ ហើយជារឿយៗ កសិករមិនដឹងថាអាចលក់ផលិតផលបាននៅកន្លែងណា។ បញ្ហាដែលកើតឡើងជាបន្តបន្ទាប់នោះ គឺថាកសិករនៅមូលដ្ឋានជាច្រើនត្រូវ ជួលកំលាំងពលកម្មពីខាងក្រៅដើម្បីជួយក្នុងការដាំដុះ និងក្នុងការប្រមូលផល ហើយប្រសិនបើលក់ផលដំណាំមិនចេញកសិករត្រូវជំពាក់បំណុលគេ។ កសិករច្រើនណាស់ត្រូវពឹងផ្អែកទៅលើការព្រមព្រៀងផ្ទាល់មាត់ពីអ្នកទិញដុំ ដើម្បីទិញផលដំណាំជាក់លាក់មួយចំនួន ហើយដែលក្រោយមក (ក្រោយពេលប្រមូលផល) ត្រូវអ្នកទិញប្រាប់ថា គេមិនត្រូវការផលដំណាំនោះទៀតទេ ហើយអ្នកទិញដុលនោះ បដិសេធមិនព្រមទិញទៅវិញ។

បញ្ហាដីធ្លីនិងបរិស្ថានមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើស្ត្រី និងស្ត្រីជនជាតិដើមភាគតិច។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការកាប់បំផ្លាញព្រៃឈើ និងការនាំចេញធនធានធម្មជាតិផ្សេងៗបានធ្វើឲ្យបរិស្ថានចុះខ្សោយ និងធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពរបស់មនុស្សរស់នៅតំបន់ជនបទ។ មានសេចក្តីស្នើច្បាប់ស្តីពីកសិកម្មនិងបរិស្ថាន ប៉ុន្តែអង្គការសង្គម ស៊ីវិលបានកត់សម្គាល់ថាច្បាប់នេះត្រូវការព្រាងឡើងវិញដោយបញ្ចូលបទបញ្ញត្តិដែលអនុញ្ញាតឲ្យអ្នកភូមិអាចទាមទារយកដី ដែលបែងចែកទៅឲ្យក្រុមហ៊ុន នៅលើដីសម្បទានសេដ្ឋកិច្ចដែលបានលុបចោលទៅហើយនោះ។

ជារឿយៗ ស្ត្រីស្ថិតនៅជួរមុខក្នុងពេលជួបជុំនិយាយអំពីបញ្ហាសិទ្ធិដីធ្លី ប៉ុន្តែត្រូវប្រឈមនឹងហានិភ័យនៃអំពើហិង្សាដែលប្រព្រឹត្តិដោយរដ្ឋ ដោយរាប់ទាំងសន្តិសុខឯកជនដែលរដ្ឋបានជួលមកផង។ កងកម្លាំងសន្តិសុខ ប្រហែលជាមិនបានទទួលការបណ្តុះបណ្តាលសមរម្យអំពីរបៀបរក្សាសន្តិភាព ដោយមិនបង្កទុក្ខទោសដល់ពលរដ្ឋដែលប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការធ្វើបាតុកម្មនោះទេ។ ឧទាហរណ៍ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ក្រុមអ្នកភូមិប្រហែល ១០០នាក់ ភាគច្រើនជាស្ត្រីដែលបាន ធ្វើដំណើរមកពីខេត្តកោះកុងមកទីក្រុងភ្នំពេញ បានធ្វើការតវ៉ាប្រឆាំងនឹងភាពអសកម្មរបស់រដ្ឋ ទៅលើករណីដីមួយកន្លែង។ កងកម្លាំងសន្តិសុខរបស់រដ្ឋ បានឡោមព័ទ្ធនិងរុញច្រានពួកគាត់។ នៅពេលដែលស្ត្រីម្នាក់ដួល ស្ត្រីផ្សេងទៀតដែលនៅជុំវិញនាង បានព្យាយាមទុកលំហ ដើម្បីឲ្យនាងបានធូរស្រាលឡើងវិញ ប៉ុន្តែ កងកម្លាំងសន្តិសុខនៅតែបន្តរុញច្រានស្ត្រីទាំងនោះដែលជាការធ្វើឲ្យស្ត្រីដែលកំពុងរបួសនោះ កាន់តែមានហានិភ័យបន្ថែមទៀត។ រដ្ឋត្រូវការអនុវត្តឲ្យបានពេញលេញនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ តាមរយៈការបណ្តុះបណ្តាលកងកម្លាំងសន្តិសុខ ប៉ូលីស យោធា និងបុគ្គលផ្សេងទៀតដែលដើរតួនាទីតំណាងឲ្យរដ្ឋ ឬធ្វើការជាមួយរដ្ឋអំពីការដោះស្រាយជម្លោះអហិង្សា ជាពិសេសនៅពេលដោះស្រាយចំពោះការជួបជុំរបស់សមាជិកសង្គមស៊ីវិល។ ការបណ្តុះបណ្តាលនេះអាចនឹងជួយទប់ស្កាត់ការតវ៉ាដោយសន្តិវិធី មិនឲ្យក្លាយជាអំពើហិង្សាតាមរយៈសកម្មភាពរបស់កងកម្លាំងសន្តិសុខ និងទប់ស្កាត់ការស្លាប់ដូចអ្នករកស៊ីផ្លូវភេទដែលមានលើកឡើងយោងក្នុងមាត្រា៦។

មាត្រា 15

# សមត្ថភាពផ្លូវច្បាប់

ស្ទើរតែគ្រប់ច្បាប់ទាំងអស់នៅក្នុងប្រទេសកម្ពុជាដូចជាស្របតាមអនុសញ្ញាស៊ីដ ដែលមិនបានរើសអើងដោយផ្ទាល់លើស្ត្រី។ នៅលើក្រដាស បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ប៉ុន្តែក្នុងភាពជាក់ស្តែង នៅតែមានការលំបាកសម្រាប់ស្ត្រីក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។

ពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យសម្បត្តិ គ្រួសារជាច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការទេ ដែលជាការលំបាកក្នុងការអះអាងអំពីសិទ្ធិដីធ្លី។ ទោះបីជាស្ត្រីជាច្រើនបានដាក់ពាក្យសុំចុះបញ្ជីដីធ្លីហើយក៏ដោយ ក៏ពួកគេបានទទួលត្រឹមតែលិខិតបញ្ជាក់ថាពួកគេមានផលប្រយោជន៍នៅលើដីនោះ។ ជាដំណើរដែលប្រើពេលវេលាកាន់តែវែង និងកាន់តែលំបាកក្នុងការទទួលបានប្លង់រឹង។ប្រសិនបើមានការប្រជែងទៅលើប័ណ្ណកម្មសិទ្ធទៅលើដីកន្លែងណាមួយនោះ វាអាចឈានចូលទៅជាសំណុំរឿងតុលាការដែលមានការពាក់ព័ន្ធយ៉ាងច្រើន។ ដោយសារតែអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ ស្ត្រីម្នាក់ត្រូវបានផ្តន្ទាទោសពីបទទន្ទ្រានដីអ្នកដទៃ ដោយកំពុងតែរស់នៅលើដីរបស់ខ្លួន។ នេះជាករណី នៅក្នុងសំណុំរឿងព្រហ្មទណ្ឌមួយដែលសូម្បីតែសំណុំរឿងរដ្ឋប្បវេណីដែលពាក់ព័ន្ធនៅតុលាការមិនទាន់បានវិនិច្ឆ័យសម្រេចនៅឡើយថាអ្នកណាជាម្ចាស់ដីពិតប្រាកដ។

បញ្ហាមួយនៅក្នុងគ្រួសារដែលមានលក្ខណៈរួមផ្សំនៃអំពើហិង្សាក្នុងគ្រួសារ ការលេងល្បែង ការប្រើគ្រឿងស្រវឹងឬការប្រើប្រាស់ថ្នាំញៀន ជារឿយៗស្វាមីដែលមានបញ្ហាញៀនថ្នាំ អាចទៅធនាគារ និងខ្ចីលុយបានដោយដាក់ប្លង់ផ្ទះបញ្ចាំដោយ មិនចាំបាច់មានការអនុញ្ញាតពីភរិយាដែលមានឈ្មោះនៅលើប្លង់កម្មសិទ្ធិដែរនោះទេ។ ជាងនេះទៀត ស្ត្រីមួយចំនួនមិនអាចបើកគណនី ធនាគារដោយឡែកបានដោយគ្មានការអនុញ្ញាតពីស្វាមីឡើយ។

**អនុសាសន៍៖**

ប្រទេសកម្ពុជា ត្រូវតែធានាឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌ ដែលបានចែងដោយរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា និងអនុសញ្ញានានា ដើម្បីឲ្យស្ត្រីទទួលបានយុត្តិធម៌ពេញលេញ។ ប្រទេសកម្ពុជាត្រូវការការលើកលែងការបង់កម្រៃ មានតុលាការចល័ត និងមានវិធានការនានាដើម្បីកាត់បន្ថយអំពើពុករលួយ។ ត្រូវការមានតម្លាភាពពេញលេញ អំពីការវិវឌ្ឍនៃសំណុំរឿងនិងលទ្ធផលនៃសំណុំរឿង។ ប្រាក់ចំណូលរបស់មន្ត្រីរដ្ឋាភិបាល ត្រូវដាក់បង្ហាញជាសាធារណៈ និងប្រាក់ខែ ត្រូវតែខ្ពស់សមល្មម ដើម្បីមិនចាំបាច់ឲ្យមន្ត្រីត្រូវពឹងផ្អែកទៅលើការងារទីពីរ ឬពឹងផ្អែកទៅលើសំណូកដើម្បីគាំទ្រដល់គ្រួសាររបស់ពួកមន្ត្រីទាំងនោះ។

# មាត្រា 16

# សិទ្ធិរៀបអាពាហ៍ពិពាហ៍

កម្ពុជាបានដកចេញនូវច្បាប់បញ្ញត្តិជាច្រើន ដែលរើសអើងលើស្ត្រី។ ឧទាហរណ៍ ភាគច្រើននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារត្រូវបានលប់ពីលើដោយក្រមរដ្ឋប្បវេណីដែលមានបទបញ្ញត្តិ អំពីអ្នកណាអាចរៀបការបានអំពីអាយុ អប្បបរមាសម្រាប់អាពាហ៍ពិពាហ៍ និងវិធានអំពីការលែងលះ និងមោឃភាពនៃអាពាហ៍ពិពាហ៍[66]។ ដូចបានលើកឡើងពីមុន មកក្នុងមាត្រា១ប្រទេសកម្ពុជាមានច្បាប់មួយចំនួន ដែលរើសអើងដោយផ្ទាល់ទៅលើស្ត្រីតាមរយៈការរឹតបណ្តឹងទៅលើពេលណាដែលពួកគេអាចរៀបការបាននិងអាចរៀបការជាមួយអ្នកណាបាន[67]។ផ្នែកមួយចំនួនក្នុងច្បាប់ស្ត្រីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ដូចបុរសដែរក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង បុរសទទួលបានអំណាចច្រើនជាងស្ត្រី។

### អាពាហ៍ពិពាហ៍កុមារ

អាពាហ៍ពិពាហ៍ភាគច្រើននៅតែមិនទាន់ផ្លូវការ ដោយការរៀបចំពិធីតាមប្រពៃណីពុទ្ធសាសនា គឺមិនមានការចុះបញ្ជីទេជាពិសេសនៅតំបន់ជនបទ។ នៅមានបញ្ហាជាហូហែអំពីអាពាហ៍ពិពាហ៍កុមារ។ សមាជិកក្នុងក្រុមជនជាតិដើមភាគតិចណាមួយ និងអ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ) ជារឿយៗទទួលរងគំនាបពីគ្រួសារឲ្យរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំដែលជាអាយុផ្លូវការ។ក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យមានអាពាហ៍ពិពាហ៍កុមារនៅអាយុ១៦ ឬ១៧ឆ្នាំ ប្រសិនបើសហព័ទ្ធម្នាក់ទៀតមានអាយុ១៨ឆ្នាំ និងមានការព្រមព្រៀងពីឪពុកម្តាយ/អាណាព្យាបាលចំពោះអាពាហ៍ពិពាហ៍នោះ។ ដោយសារតែអាពាហ៍ពិពាហ៍មិនមែនសុទ្ធតែមានការចុះបញ្ជីអាពាហ៍ពិពាហ៍នោះវាជាការលំបាកក្នុងការធ្វើអោយស្របច្បាប់ បើមិនមានការជួយពីសហគមន៍នោះ។

### ពហុពន្ធភាព

បញ្ហាមួយដែលស្ត្រីភាគច្រើនប្រឈម គឺទ្វេពន្ធភាព។ ទោះបីជាមានច្បាប់ហាមឃាត់ពហុពន្ធភាពក៏ដោយ ក៏បុរសជាច្រើនដែលមានបំណងចង់លែងលះជាមួយប្រពន្ធ បានចុះចេញពីផ្ទះទាំងស្រុង ដោយទុកប្រពន្ធ និងកូនចោល ហើយទៅចាប់ផ្តើមគ្រួសារថ្មីមួយទៀតនៅកន្លែងផ្សេង។ ក្រមរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យតុលាការអាចផ្តល់ការលែងលះ ដោយមិនមានលិខិតនោះទេ ប៉ុន្តែ អនុញ្ញាតឲ្យតុលាការធ្វើការសម្រេចទៅលើការបែងចែកទ្រព្យសម្បត្តិ សិទ្ធិចិញ្ចឹមកូន និងការទំនុកបម្រុងសហព័ទ្ធ និងកូន។ មិនទាន់មានការលើកកម្ពស់ការយល់ដឹងបានឲ្យគ្រប់គ្រាន់ អំពីការជម្រើសទាំងនេះនៅឡើយទេ ហើយស្ត្រីដែលគ្មានសំបុត្រអាពាហ៍ពិពាហ៍ផ្លូវការប្រឈមនឹងការលំបាករឹតតែខ្លាំង ក្នុងការទាមទារយកទ្រព្យសម្បត្តិ ឬការគាំទ្រ។

### សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ)

ទោះបីជាច្បាប់មិនបានហាមឃាត់ដោយផ្ទាល់ ទៅលើការរៀបអាពាហ៍ពិពាហ៍របស់បុរសស្រលាញ់ភេទដូចគ្នា[68] ក៏ដោយ ក៏ក្រមរដ្ឋប្បវេណីនៅតែយោងទៅលើស្វាមីនិងភរិយាដដែល[69] ហើយការរៀបការភេទដូចគ្នាមិនត្រូវបានទទួលស្គាល់នោះទេ។ ប្រជាជនកម្ពុជាដែលស្រលាញ់ភេទដូចគ្នាមានការចាប់អារម្មណ៍ជាពិសេស ក្នុងការចង់បានសិទ្ធិរៀប អាពាហ៍ពិពាហ៍ ស្មើភាពគ្នា និងសិទ្ធិសុំកូន ដូចដៃគូដែលមានភេទផ្ទុយគ្នាដែរ[70] ។

66 ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ មាត្រា៧៨ ចែងថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ លែងមានប្រសិទ្ធភាពហើយ លើកលែងតែមានមាត្រា ៧៦-៧៧ ទាក់ទងនឹងអាហារកិច្ច និងមាត្រា៧៩-៨១ ទាក់ទងនឹងច្បាប់ជាតិដែលគ្រប់ដណ្តប់ការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិកម្ពុជានិងជនបរទេស។

67 ទាំងនោះរួមមាន៖ ១) ក្រមរដ្ឋប្បវេណី មាត្រា៩៥០ តម្រូវឲ្យមានរយៈពេលរង់ចាំ១២០ សម្រាប់ស្ត្រីទើបលែងលះ ដើម្បីរងចាំពិនិត្យភាពមានផ្ទៃពោះសិនមុននឹងអាចរៀបការម្តងទៀតបាន, និង ២) បទប្បញ្ញត្តិដែលហាមឃាត់មិនឲ្យស្ត្រីខ្មែររៀបការជាមួយជនបរទេស ដែលរកចំណូលបានតិចជាង ២.៥០០ ដុល្លារ ក្នុងមួយខែដែលមានមានអាយុចាប់ពី៥០ឆ្នាំទៅ។

68 អតីតច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ (១៩៨៩) មាត្រា៣ កំណត់និយមន័យថា អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យារវាងបុរសនិងស្ត្រី។

69 ទោះបីជាខ្លឹមសារភាគច្រើនក្នុងជំពូកស្តីពីអាពាហ៍ពិពាហ៍នៅក្នុងក្រមរដ្ឋប្បវេណី ប្រើពាក្យ “សហព័ទ្ធ” ក៏ដោយ ក៏ក្នុងមាត្រា៩៥២, ៩៦៥, ៩៦៦ និង៩៦៧ ប្រើពាក្យ ប្តីនិងប្រពន្ធដដែល។

70 របាយការណ៍សហគមន៍ឥន្ទនូកម្ពុជានិងក្រុមហ៊ុន TNS ស្តីពី “ទស្សនៈ ឥរិយាបថ និងអាកប្បកិរិយា ចំពោះអ្នកស្រលាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា” ខែធ្នូ ឆ្នាំ២០១៥។

## Members of NGO-CEDAW:

| | Acronym | Full Name |
|---|---|---|
| 1 | ARR | Arun Reah Organization |
| 2 | CamAsean | CamASEAN Youth's Future |
| 3 | C.CAWDU | Coalition of Cambodian Apparel Workers Democratic Union |
| 4 | CATU | Cambodian Alliance of Trade Unions |
| 5 | CCFC | Coalition of Cambodian Farmer Community |
| 6 | CCIM/VOD | Cambodian Center for Independent Media |
| 7 | CCPCR | The Cambodian Center for the Protection of Children's Rights |
| 8 | CDPO | Cambodian Disabled People's Organisation |
| 9 | CDWA | Cambodian Domestic Worker Association |
| 10 | CDWN | Cambodian Domestic Worker Network |
| 11 | CFSWF | Cambodian Food and Service Workers' Federation |
| 12 | CHEC | Cambodian HIV/AIDS Education and Care |
| 13 | CLC | Cambodian Labour Confederation |
| 14 | CWCC | Cambodian Women's Crisis Center |
| 15 | CWDA | The Cambodia Women's Development Agency |
| 16 | CWLHRD | Cambodian Woman League for Human Rights and Development |
| 17 | CYN | Cambodia Youth Network |
| 18 | FAA | Fine Arts Association |
| 19 | GADC | Gender and Development for Cambodia |
| 20 | IDA | Indradevi Association |
| 21 | IDEA | Independent Democracy of Informal Economy Association |
| 22 | IHPP | Increase Health for Poor People |
| 23 | KFDA | Khmer Farmer Development Association |
| 24 | KWCD | Khmer Women's Cooperation for Development |
| 25 | LICADHO | Cambodian League for the Promotion and Defense of Human Rights |
| 26 | LSG | Lady Saving Group |
| 27 | LSCW | Legal Support for Children and Women |
| 28 | NAPA | National Prosperity Association |
| 29 | NICFEC | Neutral and Impartial Committee for Free and Fair Elections in Cambodia |
| 30 | PCC | Positive Change for Cambodia |
| 31 | RHAC | Reproductive Health Association of Cambodia |
| 32 | SC | Sunshine Cambodia |
| 33 | SKO | Srey Khmer Organization |
| 34 | VAWCC | Violence Against Women and Children of Cambodia |
| 35 | WfP | Women for Prosperity |
| 36 | WHAD | Women Health Agency Development |
| 37 | WMC | Women's Media Centre of Cambodia |